ប្រវត្តិអ្នកតស៊ូខ្មែរសម័យអាណានិគមបារាំង

## សង្ខេបឯកសារ

-ប្រវត្តិសារពត៌មាន អង្គរវត្ត របស់លោក ប៉ាចឈឺន.សឺងង៉ុកថាន់.ស៊ឹមវ៉ា
-ប្រវត្តិទៀមការហេ ខុទ្ទកការហៀខ្មែរ
-ក្បួនបាតុកម្មទាមទារលោកអាចារ្យ ហែមចៀវ
-តើទ្រង់យុត្តិវង្ស សុគតមកពីអ្វី ?
-បាតុកម្មសិស្សវិទ្យាល័យស៊ីសុវត្ថិ សម័យ « មាសសាអែម.ប៉ែមសំបូរ.បើកកាស៊ីណូ. បិទវិទ្យាល័យ. ហ៊ុយម៉ោងៗ ! »
-នរណាសម្លាប់លោកអៀវកើស ប្រធានគណៈបក្សប្រជាធិបតេយ្យ ?
-គណបក្សសង្គមរាស្ត្រនិយមជាគណបក្សទោល អស់អ្នកជំទាស់
-ការទាត់ជំនួយអាមេរិកាំង ហើយបែរទៅរកជំនួយចិនកុម្មុយនិស្ត
-ការហក្កកម្មតាមបែបកុម្មុយនិស្តចិន
-ប្រវត្តិខ្មែរសេរីមែនមែន និង ខ្មែរសេរីវៀតកុង
-សម័យសាធារណរដ្ឋខ្មែរ
-ការដកងារពីលោក សិរិមតៈ ដោយការអុបអាលរបស់អ្នកមែនលំម្លាក់
-ការវិលត្រឡប់របស់លោកសឺងង៉ុកថាន់មកកាន់គណៈរដ្ឋមន្ត្រី
-វៀតកុងធ្វើវិទ្ធង្សនានៅក្នុងសាធារណរដ្ឋខ្មែរដោយចេញមុខដោយមានការស៊ីត្រលំពីខ្មែរនេកក្នុង
-ការបង្កើតរណសិរ្សរួមជាតិឥណ្ឌូចិនដើម្បីប្រឆាំងនិងសាធារណរដ្ឋខ្មែរ
-សាធារណរដ្ឋខ្មែរបាញ់សង្គ្រាមចិត្តសាស្ត្ររបស់កុម្មុយនិស្តឥណ្ឌូចិន
-សាធារណរដ្ឋខ្មែរទម្លាក់អាវុធឱ្យខ្មែរក្រហមចូលមកសម្លាប់ប្រជាជនខ្មែរអស់ជាច្រើនលាននាក់
-ខ្មែរក្រហមមួយក្រុមប្រឆាំងនិងខ្មែរក្រហមវៀតកុងមិនឱ្យផ្ទាសប្រជាជន
-ការសម្លាប់លោកហួយន់.ហ៊ួនឹម
-វៀតកុងធ្វើជាអ្នកមកចំពង់ពីខ្មែរ បន្ទាប់ពីបានប្រគល់អំណាចឱ្យពួកខ្មែរវៀតមិញរួចហើយ

ការផ្សាយរបស់មជ្ឈមណ្ឌលក្រមង៉ុយ .ខែធ្នូ ១៩៩៥

**ម៉ុនចាន់**

**អានុស្សាវរីយ៍**

# រំលឹកប្រវត្តិ

# អ្នកតស៊ូខ្មែរ

## អ្នកណាសម្លាប់លោក អៀវកើស
## ប្រធានរដ្ឋសភា

ប៉ារីស ធ្នូ ១៩៩៥

*ការផ្សាយរបស់មជ្ឈមណ្ឌលក្រមង៉ុយ ខែធ្នូ ១៩៩៥*

## កម្រងអានុស្សាវរីយ៍

# ប្រវត្តិអ្នកតស៊ូខ្មែរ
# សម័យអាណានិគមបារាំងសែស

ប៉ារីស៍ ធ្នូ ១៩៩៥

*រៀបចំដោយ គួចសុងហាក់ និង ឈុនខៃ*
*Réalisé par KUOCH Song Hak et CHHUN Khay*
*Paris Décembre 1995*

# អារម្ភកថា

ឯកសារ «ប្រវត្តិអ្នកតស៊ូខ្មែរខ្លះៗ» នេះបានបង្ហាញយើងឱ្យដឹងម្តងទៀតថា ខ្មែរជាត្រកូលអ្នកតស៊ូ ។

ការចង់រើបម្រះចេញពីនឹមអាណានិគមនេះ,អាចចាត់ទុកជាមេរៀនមួយសម្រាប់ខ្មែរជំនាន់ក្រោយឱ្យចេះភ្ញាក់រលឹក, ចេះឈឺឆ្អាលដើម្បីស្រោចស្រង់ប្រទេសរបស់ខ្លួនឡើងវិញ ជាពិសេសនៅសម័យនេះ ។

ការដែលខ្មែរនាំគ្នារត់ល្បួចរទៅដល់ទីចាត់ការ សារ-ពត៌មាន ជាសក្ខីភាពមួយដែលបញ្ជាក់ឱ្យយើងដឹងថា ខ្មែរស្រេកឃ្លាននូវសេរីភាព,ខ្មែរដែលធ្លាប់តែត្រូវគេបំបិទមាត់ចង់ចេះ,ចង់ដឹងណាស់ នូវអ្វីដែលគេហៅថាការពិត, ភាពប្រាកដនិយម, ស្អប់ខ្ពើមនូវការអាថ៌កំបាំងគ្រប់បែបយ៉ាង ។

ខ្មែរជាអ្នកស្រឡាញ់និងគោរព អ្នកដឹកនាំរបស់ខ្លួន ។ ឯកសារនេះបានប្រាប់យើងអំពីការតស៊ូរបស់បាតុករដែលនាំគ្នាតាំងពីទីជិតឆ្ងាយ ស្អាយឆ្នាំងអំបែងរាប់យប់-រាប់ថ្ងៃ ដើម្បីមកទាមទារ តវ៉ាយកអ្នកដឹកនាំដែលស្រឡាញ់ជាតិដោយស្មោះ ។ តែអនិច្ចាណាស់, នៅទីបញ្ចប់ខ្មែរមិនទាន់បានទទួលលទ្ធផលជាទីគាប់ចិត្តនៅឡើយទេ ដោយមកពីវីរៈបុរសទាំងនោះត្រូវគេតាមយាយីធ្វើបាបរហូតដល់អស់ជីវិតរៀងៗខ្លួន ។

អ្នកនិពន្ធបានចង្អុលប្រាប់យើងអំពីនយោបាយឈ្លានពាននៃបរទេសជិតខាងដែលតែងតែចូលមកយាយីខ្មែរគ្រប់ៗ

*វេលាតាំងពីរាប់រយឆ្នាំណាស់មកហើយ ដោយប្រើមធ្យោបាយតែមួយគឺញុះញង់ខ្មែរល្ងង់ខ្លៅដើម្បីធ្វើជារនុកក្នុងរបស់វា ។ រឿង ពុតឆាយ ជាតួយ៉ាងស្រាប់ ដូចជាខ្មែរបរិវារយួនផ្សេងៗទៀតដែលបានបើកទ្វាររបងនគរខ្មែរឱ្យសត្រូវចូលដោយសេរី។ យើងឃើញថានយោបាយរបៀបនេះសត្រូវមិនដែលបោះបង់គោលជំហររបស់វាម្តងណាទេ ។*

*គួរកត់សំគាល់ថា នៅក្នុងទសវត្សនេះ អ្នកនិពន្ធខ្មែរពីរនាក់ទៀតបានខំលាតត្រដាងការឈ្លានពានរបស់សត្រូវតាមរយៈឯកសាររបស់គាត់ គឺទីមួយ ឯកសារ « នរណាជាឃាតករ ? » និង ទីពីរ « អង្គការជានរណា? » ដែលមានជាច្រើនរយទំព័រ ។*

*ជាបញ្ចប់, យើងឃើញថា នៅលើកណាៗក៏ដោយ, នៅពេលណាដែលខ្មែរធ្វើអ្វីមួយ, បរទេសជិតខាងតែងតែលូកដៃមកលាយឡំនិងរឿងរបស់ខ្មែរជានិច្ច ។*

*តទៅអនាគត, បើខ្មែរភ្លេចខ្លួន សត្រូវនឹងបន្ទំចូលមកបង្កើតជាគណៈបក្ស, ជាសមាគមយកឈ្មោះខ្មែរ, ដោយប្រើខ្មែរឬកូនកាត់យួនខ្មែរជាអ្នកធ្វើ ហើយវាពួននៅពីក្រោយខ្នងយើង ចាំញាក់ខ្សែឱ្យខ្មែរធ្លាក់ឆ្ពោះទៅរកគោលដៅដ៏ខ្មៅក្រខ្វក់របស់វា ។*

*ប៉ារីស៍ មករា ១៩៩៥*

*មជ្ឈមណ្ឌលក្រមង៉ុយ*





# ប្រវត្តិអ្នកតស៊ូខ្មែរខ្លះៗ ក្នុងសម័យអាណានិគមបារាំង (1)

ខ្ញុំសូមជំណាលជំរាបកូនចៅខ្មែរ ឱ្យបានជ្រាបអំពីប្រភពកំណើតសារពត៌មាន« *អង្គរវត្ត* (2) »ដែលមានលោក *ប៉ាចឈឺន* ជាចាងហ្វាង. សូមលោកអ្នកនាងជ្រាបដូចតទៅនេះ :

មុនដំបូង,រូបខ្ញុំបានជួយដើមទុនខ្លះឧបត្ថម្ភលោក *ប៊ុនច័ន្ទម៉ុល* ដែលមិនបានរៀនសូត្រអ្វីឆ្ងាយទេ ។

តែលោកមានសេចក្តីក្លាហានណាស់ ហើយថែមទាំងជាកីឡាករខាងប្រដាល់ម្នាក់ដែលតែងតែឡើងប្រឡងប្រជែងនៅវាលមេរុំជារៀងរាល់ពេលចូលឆ្នាំខ្មែរផង ។ គាត់ជាកូនលោកឧកញ៉ា *ប៊ុនច័ន្ទមង្គល* ហើយលោក ប៊ុនច័ន្ទមង្គលជាកូនប្រសារលោកមហាមន្ត្រី *ប៉ុកឌុច* ។

លោកប៊ុនច័ន្ទម៉ុលមានបងប្អូន៩នាក់, ប្រុស៦នាក់,ស្រី៣នាក់ ។ លោកស្រីប៊ុនច័ន្ទមុល្លីជាភរិយារបស់លោក *ជួនហ៊ល* (កូនសម្តេច *ជហ្វាវាំងជួន* ) ។ ក្នុងចំណោមបងប្អូនលោក

---

*(1) កាលណោះលោកសឹងម៉ុកថាន់ធ្វើការនៅក្រសួងពុទ្ធសាសនបណ្ឌិត, លោកប៉ាចឈឺនធ្វើការនៅហាងលក់រថយន្ត ហ្គារ៉ាសហ្សង់កុងប៉ឺហ្ស (Garage Jean Compte -Peugeot), លោក អៀវកើស ធ្វើការច្រើនកន្លែង មាននៅចំការកៅស៊ូតំបន់ ដប់-មេមត់ កំពង់ចាម ជាដើម ។ លោក ស៊ីមវ៉ា ធ្វើការនៅក្រសួងទ្រីប៊ុយណាល់ (tribunal) បារាំង. លោក ជុំមួង.នួនមួង ធ្វើការនៅប៉ុយ្ស៍ ដេឡូហ្គេស៍ នៅមុខវាំង.លោកប៊ុនច័ន្ទម៉ុលជាម្ចាស់ហាងកាហ្វេ. ប៊ុនថាន់នី ជាម្ចាស់ហាង តេនប៊ុនថាន់ នៅផ្សារស៊ីឡែក។ល។*

*(2) កើតក្នុងរវាងឆ្នាំ ១៩៣៦ ហើយគ្មានចំនាក់ចំនងអ្វីនឹងកាសែត អង្គរវត្តនៅស្រុកបារាំងសព្វថ្ងៃ (ឆ្នាំ១៩៩៥) នេះទេ ។*

ប៊ុនច័ន្ទម៉ុល.មានលោក *ប៊ុនច័ន្ទថ្ងង់* រៀនសូត្របានល្អលាស់ជាងគេ ។

កាលបើឃើញលោក ប៊ុនច័ន្ទម៉ុល ដើរតែលគោលគកការធ្វើផ្លូវប្លោះ.ខ្ញុំក៏បបួលឱ្យរៀបចំចាត់ចែងបង្កើតកៀមកាហ្វេខ្មែរមួយនៅផ្សារ *ស៊ីតែវ៉ុក* ដើម្បីប្រមែប្រមូល.ទាក់ទាញពួកជាងនៅសាលារថនាផង.ពួកអ្នកធ្វើការនៅ*ពូទសាសនបណ្ឌិត* ផង។ យើងមានគ្នាពនាក់ ។ លោកប៊ុនច័ន្ទម៉ុលចូលដើមទុន២០០រៀល. លោក*ប៉ុណ្ណក៏ហោង*២០០រៀល.ឯរូបខ្ញុំ៣០០រៀល ។

ផ្ទះកាហ្វេនេះក៏ចាប់កំណើតឡើង.ដែលមានរូបខ្ញុំជាអ្នកឧបត្ថម្ភគ្រប់សព្វដោយមិនយកចំណេញទេ ព្រោះចង់ឱ្យលោកទាំងពីរនាក់ខាងលើនេះមានការធ្វើ ។

ផ្ទះកាហ្វេនេះមានឈ្មោះថា : *ឧទ្ទកកាហ្វេខ្មែរ* មានទីតាំងនៅអតីតផ្លូវប៉ាវី(Pavi)បែរមុខទៅវាលមេរុំ.ខាងជើងព្រះបរមរាជវាំង ។

ការបង្កើតផ្ទះកាហ្វេនេះបានផលជាក់ស្តែង ជាទីគាប់ចិត្តណាស់ ។ លោក *ប៉ាចឈឺន*, លោក *ស៊ឺងង៉ុកថាញ់* ព្រមទាំងអស់លោកខ្មែរៗ ពីទីជទៃខ្លះ មកជួបជុំគ្នានៅផ្ទះកាហ្វេនេះជារៀងរាល់ថ្ងៃ ។ មុននឹងចូលទៅធ្វើការក្តី, ពេលចេញពីធ្វើការក្តី អស់លោកទាំងនោះតែងតែមកអង្គុយជជែកគ្នាលេងនៅទីនេះជាធម្មតា ។

នៅក្នុងផ្ទះកាហ្វេនេះ គេមានដាក់រូប ក្បាលខ្លែមួយ ជាសញ្ញា ។ កាលណារូបនេះនៅលើទីតាំង.អ្នកទាំងអស់គ្នាមិនត្រូវនិយាយពីរឿងនយោបាយទេ ។ កាលបើឃើញរូបក្បាលខ្លែ





នេះហើយ.អ្នកដែលចូលទៅផឹកកាហ្វេទាំងប៉ុន្មានត្រូវតែផ្លាស់ប្តូរពាក្យសំដីមករឿងធម្មតាទៅវិញ ។

ផលនៃការជួបជុំគ្នានេះ, អាចធ្វើឱ្យមនុស្សចេះភ្ញាក់រឭក.និកឃើញភាពលំបាកថោកទាបដែលជាខ្ញុំកញ្ជះគេ ។ ដូច្នេះហើយអ្នកទាំងនោះក៏កើតគំនិតចង់រើបម្រះពីនឹមនេះប្រៀបបីដូចទៅនឹងសត្វដែលចង់ហើរចេញពីទ្រុងដូច្នោះឯង ។

ការដែលនាំឱ្យមានកំណើតកាសែត *អង្គរវត្ត* នេះគឺចេញមកអំពីផ្ទះកាហ្វេនេះឯង ។កាលដើមដំបូងមានលោក ស៊ឺងង៉ុក-ថាន់.លោក ប៉ាចឈឺន.លោក ជុំមួង, លោកស៊ឹមវ៉ានាំគ្នាគិតករតាំងឡើងជាក្រុមហ៊ុន ។ គេកំណត់ហ៊ុនមួយហ៊ុនៗចំនួនជាទឹកប្រាក់ ៥រៀល (Piastres (1)) ។ ព្រោះខ្មែរនៅពេលនោះមិនសូវមានលុយកាក់បរិបូរណ៍ទេ.តែគេមានចិត្តខំតស៊ូនិងសាមគ្គីក្នុងរឿងជាតិណាស់ ។

រូបខ្ញុំមានវ័យចាស់ជរាណាស់ទៅហើយ, ហើយដើម្បីជូនកូនចៅខាងក្រោយបានជ្រាប.ខ្ញុំនឹងដំណាលជំរាបពីរឿងដែលកាលនៅពេលនោះមានរូបខ្ញុំម្នាក់បានដឹង.បានឃើញ និង បានជួយជ្រោមជ្រែងផងដែរ ដូចតទៅនេះ :

អស់លោកទាំងប៉ុន្មាននាក់ខាងលើនេះ ក៏ខំប្រឹងរួមកម្លាំងគ្នាឡើងបង្កើតបានសារពត៌មាន *អង្គរវត្ត* នេះ ក្នុងគោលគំនិត

---

*(1) គឺលុយរៀលក្នុងជំនាន់នោះដែលចាយបានក្នុងឥណ្ឌូចិន (បីប្រទេស) គឺប្រទេសកម្ពុជា.លាវនិងយួន ។ នៅក្នុងសម័យនោះ ធនាគារឥណ្ឌូចិន ជាអ្នកបានបោះពុម្ពបីយ៉េបណ្ណនេះ.ហើយគឺសេដ្ឋកិច្ចទាំងបីប្រទេសនេះហើយដែលទ្រទ្រង់តម្លៃប្រាក់ (Piastre) ។ ធនាគារកណ្តាលមានទីស្នាក់ការនៅទីក្រុងហាណូយ ( យួនហ្វេ) ។ មន្ត្រីធំបារាំងត្រួតលើប្រទេសទាំងបីគេហៅថា ហ្គូវែរណឺរយ៉េណេរ៉ាល (Gouverneur général) មានទីស្នាក់ការនៅក្រុងហាណូយ ។ នៅទីក្រុងភ្នំពេញ និង វៀងច័ន្ទ គេហៅថា រ៉េស៊ីដង់ស៊ុបពេរីយ៉ើ (Résident supérieur) ។*

សម្រាប់ដាស់តឿនក្រើនរំឭកយុវជន-យុវនារីខ្មែរជំនាន់ក្រោយ ឱ្យមានការឈឺចាប់ភ្ញាក់រឭក ព្រោះកាលណោះ យើងរស់នៅក្រោមបង្គាប់បារាំងសេស ។ ខ្មែរនៅពេលនោះមានសេចក្ដីលំបាកវេទនាដោយមកពីការកៀបសង្កត់ តាមឧបាយកលផ្សេងៗ ធ្វើឱ្យយើងមានការឈឺចាប់ណាស់ ពុំហ៊ានមាត់-ក. និយាយស្ដីអ្វីនឹងគេទេ ។

មុនដំបូងគេបានរៀបចំចែកថ្នាក់សមាជិក តាមថ្នាក់ការងារដែលត្រូវធ្វើ :

ទី១ : <u>សមាជិកក្រុមអភិបាល</u> :
មានលោក *ប៉ាចឈឿន* ជាចាងហ្វាង.លោក *ស៊ឹមអ៊ុកថាន់. អៀវកើស.ស៊ីមវ៉ា.ម៉ៅហ៊ុង.ជុំមួង.នួនដួង* ជាអ្នកចាត់ចែងអត្ថបទ និង រៀបចំទំព័រកាសែត ។

ទី២ : <u>យុត្តិកសមាជិក</u> :
មានលោកអាចារ្យ *ហែមចៀវ* (1).*ខៀវជុំ* (1).*ប៉ាងខាត់* (1). *ប៊ុនច័ន្ទម៉ុល.ប៊ុនថាន់. ទេពប៉ាន. ជាងលាន. មិញណាគ្រី*។ល។ ជាអ្នកឃោសនានិងដើរបបួលរកសមាជិក ឱ្យបានកាន់តែច្រើន សម្រាប់ហ៊ុនផងសម្រាប់អ្នកគាំទ្រផង ព្រមទាំងដាស់តឿនរំឭកប្រជាជនឱ្យចេះរួបរួមសាមគ្គីគ្នា ។ ចំណែកខាងព្រះសង្ឃ មានលោកអាចារ្យ ហែមចៀវ.ខៀវជុំ.ប៉ាងខាត់ កាលបើមានគេនិមន្តទៅបុណ្យឯណាម្ដងៗ លោកតែងតែឆ្លៀតឱកាសនោះពន្យល់រំឭកដាស់តឿនទាយក.ទាយិកាក្នុងធម្មទេសនារបស់លោកជារៀងរាល់ពេល ។ មានថ្ងៃមួយនោះ, លោកបានចូលទៅទេសនានៅក្នុងពន្ធនាគារ ដែលមានអ្នកទោសជាច្រើន ។

(1) *ជាព្រះសង្ឃ*





ដោយអំណាចធម្មទេសនានោះ,អ្នកទោសទាំងឡាយ ក៏ផ្អើលជ្រួលច្របល់, ភ្ញាក់រឭកក្រោកឡើងព្រួតគ្នាវាយកម្លូកនិងឆ្មាំគុក ហើយរត់ចេញបានជាច្រើននាក់ ។ អ្នកខ្លះត្រូវគេចាប់បានបញ្ចូលគុកវិញ.អ្នកខ្លះបានរត់គេចរួចខ្លួនមក ។ ចាប់តាំងពីថ្ងៃនោះមក,គេក៏ឈប់និមន្តលោកឱ្យទៅទេសនាប្រៀនប្រដៅទៀតហើយ ។

ទី៣ : <u>បាសាទិកសមាជិក</u> : ដែលគ្រាន់តែមានឈ្មោះជាអ្នកគាំទ្រ ។

& &
&

លោក ប៊ុនច័ន្ទម៉ុលតែងតែឃោសនាពន្យល់អ្នកមកផឹកកាហ្វេជានិច្ចជាកាល ។ ចំណែកឯរូបខ្ញុំដែលជាជាងរចនាគ្រឿងមាសប្រាក់ (1) , តែងតែចេញចូលជារឿយៗធ្វើរបស់របរសម្រាប់រាជវាំង ។

នៅពេលមួយខ្ញុំឆ្លៀតឱកាសថ្វាយទូលសម្ដេច *ពិណ្ណូរ៉ា* អំពីកំណើតនៃកាសែតអង្គរវត្តនេះ ដែលមានឧត្ដមគតិសម្រាប់បំភ្លឺណែនាំខ្មែរទូរទាំងប្រទេស ឱ្យចេះស្រឡាញ់ ជាតិ.សាសនានិងព្រះមហាក្សត្ររបស់ខ្លួន ។ សម្ដេច ព្រះពិណ្ណូរ៉ា ដែលត្រូវជាព្រះអនុជ *ព្រះបាទមុនីវង្ស* បានប្រទានប្រាក់ចំនួនមួយពាន់រៀល (១000រៀល - 1000 Piastres ) ដល់កាសែត អង្គរវត្ត ។ ខ្ញុំបាន

(1) *សូមអញ្ជើញអាន « ជីវប្រវត្តិរបស់លោកតាប៊ុនថាន » បោះពុម្ពដោយមជ្ឈមណ្ឌលក្រមអ៊ុយ ៨៨ ទំព័រ ខែកញ្ញា ១៩៩៥ ។*

អញ្ជើញលោកប៉ាចឈឺនឱ្យមកទទួលប្រាក់នេះពីផ្ទាល់ព្រះហស្ត សម្តេចពិណ្ឌុរ៉ា ។ ប្រាក់ចំនួនមួយពាន់រៀលជំនាន់នោះ មានតម្លៃណាស់ ជាហេតុធ្វើឱ្យអស់លោកអ្នកទទួលខុសត្រូវ ខាងកាសែតព្រេកអរនឹងខ្ញុំជាក្រៃលែង ។

កាសែត អង្គរវត្តមានប្រជាប្រិយភាពសម្បើមណាស់ ។ នៅពេលដំបូងគេចេញចំនួន ៥០០ច្បាប់.មួយលើកម្តងក្នុងមួយអាទិត្យ ។ នៅលើកទី២គេចេញចំនួន១០០០ច្បាប់ ។ ចំនួននេះនៅតែមិនគ្រប់គ្រាន់នឹងសេចក្តីត្រូវការលោកអ្នកអានទេ ព្រោះនៅពេលនោះ.អ្នកនៅខេត្តក្រៅក៏សុំជាវជាសទ្ធិកសទ្ធាប់ដែរ ។ ពីរខែក្រោយមកគេចេញចំនួន ៧០០០ច្បាប់.ក្នុងមួយលើកៗ ។ ការដែលចេញមានចំនួនច្រើនយ៉ាងនេះ ធ្វើឱ្យបារាំងមានសេចក្តីចាប់អារម្មណ៍ ... ។

បារាំងក៏ចាត់ការត្រួតពិនិត្យមើលសិនមុននឹងចេញ ។ ពេលខ្លះគេមិនពេញចិត្តនឹងអត្ថបទដែលកាសែតបំរុងចុះផ្សាយ.បារាំងក៏បង្គាប់ឱ្យដកចេញ ។ កន្លែងដែលត្រូវចុះក៏នៅចំហរទទេ ។អ្នកអានក៏ផ្ញើលទៅសូមមើលអត្ថបទដល់ទីចាត់ការសារពត៌មាន ។ បារាំងឃើញដូច្នោះ.គេក៏កោះហៅ លោកប៉ាចឈឺន ទៅម្តងទៀតបង្គាប់ឱ្យរកអ្វីយកមកចុះបំពេញ កុំទុកចំហរ ។ ការចេញកាសែតក៏មានការរអាក់រអួលដោយត្រូវប្រើពេលយ៉ាងយូរ.ទម្រាំនឹងដកចេញ. ដាក់ចូលអត្ថបទនិមួយៗពេលវេលាក៏ត្រូវប្រើលើសពីមួយអាទិត្យគឺគេធ្វើបាបយើងយ៉ាងណាកុំឱ្យយើងមានអ្នកអានច្រើនតទៅទៀត ។

ហេតុនេះ. នៅក្នុងពេលឥឡូវនេះ សូមកូនចៅខ្មែរទាំង





ឡាយមេត្តាជ្រាបថា : បើប្រទេសយើង «ខ្ញុំគេ »ហើយយើងច្បាស់ជាអស់មានសេរីភាពក្នុងការបញ្ចេញយោបល់ហើយ។

ចំណែកឯព្រះសង្ឃ ហែមចៀវ. ព្រះអង្គបានភ្ញាក់រឭកនឹកឃើញការថោកទាប.ខាត ចំណេញ មុនគេ ។ ជារៀងរាល់យប់លោកតែងតែរួមប្រជុំព្រះសង្ឃនិងឧបាសកខ្លះៗនៅក្រោមកុដិដើម្បីរកការដោះស្រាយ រកគម្រោងការណ៍នឹងរើបម្រះចេញពីអំណាចបារាំង ។ ព្រោះនៅពេលនោះលោកអាងទៅលើអានុភាពរបស់ជប៉ុនដែលមានអំណាចមកលើបារាំង ។

ខាងកាសែត អង្គរវត្ត ក៏ខិតខំរកចំណុចខ្សោយរបស់បារាំងយកមកចុះផ្សាយឃោសនាដើម្បីឱ្យខ្មែរភ្ញាក់រឭក ។ នៅឯកៀមកាហ្វេរបស់លោកច័ន្ទម៉ុល.ទាំងអស់គ្នានិយាយតែពីរឿងជាតិជារៀងរាល់ថ្ងៃ ។


លោក សឺងង៉ុកថាញ់

# ក្បួនបាតុកម្មនាមនារ លោកអាចារ្យហែមចៀវ

មានថ្ងៃមួយមានបារាំងម្នាក់ឈ្មោះ*ម៉ៀវ៉ាកិះ* បានចូលទៅក្រាបទូលសម្តេច*ជួនណាត*សូមរៀន«សំណាក់ធម៌កម្មដ្ឋាន » ក្នុងចេតីយ៍ក្រោយព្រះវិហារវត្តឧណ្ណាលោម ។ បារាំងនេះមិនបានរៀនធម៌អីទេព្រោះជារៀងរាល់យប់ពីម៉ោង៩យប់ទៅ១១ អាធ្រាត្រ ក្នុងឋានៈជាអាំងស្ប៉ិចទ័រតិញ, គាត់តែងតែដើរសង្កេតការណ៍ ក្នុងវត្តគ្មានលោះមួយយប់ណាឡើយ ។ លោកសង្ឃនិងអ្នកឯទៀតឃើញអាកប្បកិរិយាបារាំងនេះ ដែលគួរឱ្យសង្ស័យ ក៏នាំគ្នាឡើងទៅទូល លោកអាចារ្យហែម-ចៀវ ។ លោកអាចារ្យហែមចៀវក៏ចាត់រូបខ្ញុំឱ្យឡើងទៅទូលសម្តេចជួនណាតតាមហេតុដែលខ្ញុំបានឮមក ។ សម្តេចជួនណាត បានជ្រាបហើយ ក៏បដិ-សេធពុំព្រមយល់តាមការដែលខ្ញុំបានទូលនោះទេ ។ លោកមានសង្ឃដិកាថា :

-អាត្មាបានស្គាល់បារាំងនេះច្បាស់ណាស់.គាត់ថែមទាំងសុំអាត្មាបួសទៀតផង ។ ខ្ញុំក៏ទូលលោកទៅវិញថា :

-ខ្ញុំព្រះករុណាល្ងង់ណាស់.អ្វីៗជឿតាមសម្តេចមានបន្ទូលទាំងអស់ ។ ការដែលខ្ញុំព្រះករុណាចូលមកគាល់ទូលសម្តេចនេះព្រោះខ្ញុំព្រះករុណាចាំព្រះបន្ទូលសម្តេចទេសនាថា :

-កុំទុកចិត្តជនបរទេស. កុំទុកចិត្តអភិនេស្រ្កម៍. កុំទុកចិត្ត





អភិប្រាយ (1)។ ពាក្យនេះ ដែលជាព្រះបន្ទូលរបស់សម្តេច ។ នៅពេលនោះ.សម្តេចជួនណាតឆ្លើយមកខ្ញុំវិញថា :

-លោកកុំភ័យចំពោះបារាំងនេះ. ឯបារាំងណាៗទៀតអាត្មាមិនដឹងទេ ។ល។

& &
&

ក្រោយមកប្រមាណជាពីរខែតែប៉ុណ្ណោះ ស្រាប់តែបាត់កូនសិស្សអាចារ្យហែមចៀវ ពីកុដិ ពីរថ្ងៃមិនឃើញមកបម្រើលោក. មកស៊ីបាយក៏មិនឃើញមក ។ កន្លងមកប្រមាណជាពីរ-បីថ្ងៃ ស្រាប់តែនៅម៉ោង៩ព្រឹកមានពួកគិញបើកឡានចូលមកចាប់លោកអាចារ្យហែមចៀវនៅសាលាបាលីជាន់ខ្ពស់.លោកជុំមួង. លោកនួនដួង ពីរនាក់ទៀតនៅក្រសួងដេឡេហ្គេស៍ មុខវាំង យកទៅឃុំនៅក្រសួងប៉ូលីស៍បារាំង ។ ចំណែកឯលោកអាចារ្យហែមចៀវ គេនាំយកទៅប្រគល់ ឱ្យលោក *ទាសាន* រដ្ឋមន្រ្តីក្រសួងមហាផ្ទៃឱ្យនាំទៅសូមអនុញ្ញាតពីសម្តេចសង្ឃជួនណាតផ្សឹកចេញពីភេទព្រះសង្ឃមកជាគ្រហស្ថវិញ ។ លុះកន្លងមក

---

*(1) អភិនេស្រ្កម៍ គឺអ្នកបួសស្វែងរកព្រហ្មចរិយធម៌ប្រាសចាកទ្រព្យសម្បត្តិផងទាំងពួង. អភិប្រាយ គឺ សេចក្តីអធិប្បាយ ។កុំទុកចិត្តអ្នកបួស.កុំទុកចិត្តសេចក្តីអធិប្បាយរបស់មនុស្ស ។ ពាក្យនេះចាស់ទុំប្រដៅខ្មែរជំនាន់ក្រោយឱ្យប្រុងប្រយ័ត្នក្រែងមានពួកចោរ ឬពួកអ្នកទិលខូចខ្ជិលធ្វើការរកស៊ីឬពួកបរទេសជិតខាង ចូលមកបន្លំធ្វើជាអ្នកបួសក្លែងក្លាយដើម្បីពន្លិចពុទ្ធសាសនាដែលខ្មែរតែងតែគោរពបូជា ។ កុំទុកចិត្តអភិប្រាយគឺកុំទុកចិត្តពាក្យឃោសនារបស់អ្នកនយោបាយនានាឬអ្នកឃោសនាលក់ថ្នាំកែរោគជាដើម ដែលពួកគេប៉ិនប្រសប់រកពាក្យណាៗដាក់ឱ្យចំចំណុចខ្សោយរបស់យើងម្នាក់ៗឱ្យយើងលង់ខ្លួន ដើម្បីបម្រើប្រយោជន៍របស់គេតែប៉ុណ្ណោះ ។*

ពីរថ្ងៃពួកបាតុករខ្មែរទាំងព្រះសង្ឃ, ទាំងគ្រហស្ថរាប់ម៉ឺននាក់ធ្វើបាតុកម្មទាមទារយកលោកអាចារ្យហែមចៀវ ។ ក្បួនដង្ហែចាប់តាំងពី *វត្តលង្ការ* តាមផ្លូវ *នរោត្តម* មកដល់វិទ្យាល័យស៊ីសុវត្ថិ, មានប្រវែងជិតមួយគីឡូម៉ែត្រ សុទ្ធសឹងតែហ្វូងមនុស្សពេញទាំងអស់ ។ លោក ប៉ាចឈឿន កាន់ទង់ជាតិនាំមុខគេដើរទន្ទឹមលោកសឺងង៉ុកថាន់ ។ គេហែដើរសំដៅទៅកាន់ប៊ុយរ៉ូរេស៊ីដង់ស៊ុបេរីយ័រ (1) ក្រោយវត្តភ្នំដូនពេញដើម្បីទាមទារយកអាចារ្យហែមចៀវមកវិញ ។

អំពីការរៀបចំបាតុកម្ម, គេស្រុះស្រួលគ្នាយ៉ាងប្រសើរបំផុត ។ លោកអាចារ្យប៉ាំងខាត់ ជាអ្នកដឹកនាំធ្វើមួយយប់ទើសភ្លឺ ។ គេសរសេរខិត្តប័ណ្ណ មួយពាន់សន្លឹកសរសេរដោយដៃទាំងអស់, ហើយចែកឱ្យរទះកង់ចំនួន២០, កង់មួយៗកាន់៥០សន្លឹកយកទៅចែកតាមវត្ត, តាមភូមិនិងតាមសង្កាត់ទាំងអស់ ឱ្យទៅប្រជុំគ្នានៅវត្តលង្ការ ។

លុះក្បួនបាតុកម្មបានដង្ហែទៅដល់ប៊ុយរ៉ូ រេស៊ីដង់ស៊ុបេរីយ័រហើយ, មានបារាំងជាច្រើននាក់រង់ចាំនៅទីនោះ ។ លោកប៉ាចឈឿនក៏ដកយកក្រដាសមកអានតវ៉ាយកអាចារ្យ ហែម-ចៀវ មកវិញ ។ បារាំងបដិសេធមិនព្រមហើយឆ្លើយថា ចាំគេពិនិត្យមើលសិន ព្រោះពេលនេះដោះលែងទៅមិនទាន់បានទេ ។ លោកប៉ាចឈឿននៅតែទទូចទាមទារមិនឈប់ ។ បារាំងក៏ទាញដៃបម្រុងយកលោកប៉ាចឈឿន, តែលោកសង្ឃក៏ចូលទៅដណ្តើមយកលោកមកវិញ ។ បារាំងទាញទៅ, បាតុករទាញមកប្រទាញប្រទង់គ្នា ។ លោកសង្ឃក៏យកដងឆ័ត្រចាក់បារាំង។

(1) *Bureau du Résident Supérieur*





ចំណែកឯលោកប៊ុនច័ន្ទម៉ុលក៏លើកកង់បោកទៅលើបារាំងដែរ។ បារាំងត្រូវរបួសដោយសារឆ័ត្រព្រះសង្ឃផង, ដោយសារកង់លោកប៊ុនច័ន្ទម៉ុល ផង ។ ពួកបាតុករ កាន់តែមូលមកជាច្រើនដេរដាស ។ បារាំងឃើញដូច្នោះក៏យកកាំភ្លើងមកបាញ់រះបី-បួនគ្រាប់ឡើងលើកំពើញ ។ ពួកបាតុករក៏ដកថយអស់ទៅ ។

នៅយប់នោះក្រុមតម្រួតនិងគិញបារាំងបើករថយន្តដេញចាប់ពួកបាតុករប្រវ៉ាត់ពេញទីក្រុងភ្នំពេញ ។ នៅពេលនោះគេចាប់បាន លោកអាចារ្យប៉ាំងខាត់ និង លោកប៊ុនច័ន្ទម៉ុល ។ ចំណែក លោកអាចារ្យខៀវជុំ លោកអាចារ្យសុខ និង លោកជាងលាន រត់ចូលទៅប្រទេសថៃ ។ ខ្លួនខ្ញុំនិង ជាងទេពប៉ាន ក៏គេចខ្លួនទៅពួននៅស្រុកស្វាយពល ខេត្តព្រៃវែង ។ រីឯលោកសឺងង៉ុកថាន់រត់ទៅពួននៅអេតាម៉ាហ្ស៊័រ (1) ជប៉ុន ។ អ្នករត់គេចខ្លួននិងអ្នកដែលគេចាប់បាននោះមានច្រើនណាស់, ខ្ញុំមិនអាចចាំនិងស្គាល់ឈ្មោះអ្នកទាំងអស់នោះទេ ព្រោះពេលវេលាបានកន្លងមកជាងកន្លះសតវត្សទៅហើយ ។ ឯផ្នែកខាងរោងពុម្ពសារពត៌មានអង្គរវត្តវិញ, បារាំងចាត់ការឱ្យគេទៅរើកកាយ, វាយបំបែកបំបាក់ ហើយបោះចោលទាំងអស់គ្មានសល់អ្វីទេ។ ចំណែកឯអ្នកដែលត្រូវគេចាប់បាន គេក៏បញ្ជូនទៅដាក់គុកនៅឯព្រៃនគរទាំងអស់ គ្មានទុកនៅស្រុកខ្មែរម្នាក់ទេ ។លោកអាចារ្យហែមចៀវនិងលោកប៊ុនច័ន្ទម៉ុលក៏ត្រូវបារាំងយកទៅដាក់គុកនៅកោះត្រឡាច ។ លោកប៊ុនច័ន្ទម៉ុលបាននិយាយប្រាប់ខ្ញុំថា លោកអាចារ្យហែមចៀវគង់នៅក្នុងគុកកោះត្រឡាច បានតែ៦ខែទេ លោកក៏សុគតនៅក្នុងគុកទៅ ។ គេដាក់ឱ្យសង្កើចខាំលោក,

(1) *Etat major*

លោកកើតកមរមាស់ពេញខ្លួន,សឹង្គមិនបានក៏សុគតទៅ ។ ចំណែកលោកអាចារ្យចាំងខាត់,គេដាក់គុកលោកនៅព្រៃនគរ ។ លោកសឺងង៉ុកថាន់ ត្រូវជប៉ុន នាំយកទៅស្រុកគេឱ្យរៀនភាសាជប៉ុន ។ លុះដល់ជប៉ុនចាប់បារាំងអស់ហើយ,គេក៏នាំលោកសឺងង៉ុកថាន់ មកវិញដើម្បីរៀបចំគណៈរដ្ឋមន្ត្រី ដែលមានរូបលោកជានាយក ។

លោកជុំមួង ចាប់ផ្ដើមបង្កើតកងទ័ពខ្មែរ ដែលមានជប៉ុនជាអ្នកជួយបង្រៀន ។

លុះគេបង្កើតគណៈរដ្ឋមន្ត្រីថ្មីបានហើយ, គេក៏ចាត់ចែងទៅដោះលែងអ្នកដែលបារាំងចាប់យកទៅទាំងប៉ុន្មានមកវិញទាំងអស់ ។ លោក ប៊ុនច័ន្ទម៉ុល ត្រូវមានភារៈកិច្ចទៅគាស់យកសពលោកអាចារ្យហែមចៀវពីកោះត្រឡាចដើម្បីមកធ្វើបាំរាយ៍តបូជានៅមុខវត្ត ឧណ្ណាលោម ទៅតាមប្រពៃណីព្រះពុទ្ធសាសនា ។

គណៈរដ្ឋមន្ត្រីលោក សឺងង៉ុកថាន់ ធ្វើការមិនបានយូរប៉ុន្មាន,ជប៉ុនត្រូវចាញ់សង្គ្រាមដោយសារអនុភាពបរិមាណូរបស់កងទ័ព អាមេរិកាំង ។ ពេលនោះត្រូវកងទ័ពសម្ព័ន្ធមិត្ត (1) ចូលមកត្រួតពិនិត្យអាវុធជប៉ុននៅប្រទេសខ្មែរ ។ នៅពេលនោះលោកហ្សេណេរ៉ាលបារាំងឡឺក្លែរ៍ (2) បានចាត់ការឱ្យគេអញ្ជើញលោក សឺងង៉ុកថាន់ មកជួបនៅទីស្នាក់ការកណ្ដាលក្រុងភ្នំពេញ ។ លុះពេលលោកមកជួប, គេក៏ចាប់លោកបញ្ចេញតាមទ្វារក្រោយនាំដាក់កប៉ាល់ហោះយកមកដាក់គុកនៅស្រុក

---

*(1) កងទ័ពសម្ព័ន្ធមិត្តមាន ៥ប្រទេស : អាមេរិកាំង,កាណាដា,បារាំង,អង់គ្លេស,ចិន*
*(2) Général Leclerc*





បារាំង ។ ពេលនោះបារាំងមានការកាចសាហាវខ្លាំងជាងមុនណាស់ ។ អ្នកណាគាំទ្រលោក សឺងង៉ុកថាន់ ទាំងប៉ុន្មានត្រូវបានរងគ្រោះមួយសារទៀត គឺបារាំងដើរប្រមូលចាប់យកទាំងអស់ ។ អ្នកជាប់ទោសពីមុនដែលបានរួចខ្លួនមកហើយក្ដីក៏ត្រូវគេចាប់ដាក់គុកវិញទាំងអស់ ។ អ្នកខ្លះដឹងខ្លួនទាន់ក៏រត់គេចទៅ ។ លោកប៊ុនច័ន្ទម៉ុល រត់គេចចេញទៅស្រុក ស្វាយ-ដូនកែវ,ខេត្តបាត់ដំបងដែលកាលណោះស្ថិតនៅក្នុងកណ្ដាប់ដៃនៃប្រទេសថៃ ។ ចំណែកលោក*សុវណ្ណហ្វូត* ជាភូឈ្មួយ លោកសឺងង៉ុកថាន់ដែលត្រូវជាកូនលោកគ្រូពេទ្យហួត,ត្រូវគេចាប់បាន ។ គេយកលោកទៅវាយសម្លាប់នៅក្នុងគុក រួចហើយគេយកខ្សែចមកចងព្យួរនៅតាមមាត់បង្អួចដើម្បីបង្ហាញថា លោកចង-កសម្លាប់ខ្លួនឯង ។ គឺនៅពេលដែលបារាំងត្រឡប់មកលើកទី២នេះហើយដែលមានខ្មែរខ្លះបង្កើតបានជា «ក្រុមខ្មែរឥស្សរៈ»។ អ្នកបង្កើតក្រុមនេះមាន *ទ្រង់ច័ន្ទរង្សី*,លោកស័ក្តិ១ធីង បង្ករទ័ព នៅខេត្តកំពង់ស្ពឺ ។ ប៉ែកខាងកើតភ្នំពេញ,ឈ្មោះអាចារ្យយី តាំងទ័ពនៅក្នុង ឃុំអារីយ៍ក្សត្រ ។ ប៉ែកខាងបាត់ដំបង, មានឈ្មោះ *ហ៊ុលវង្សអានុភាព*, លោក ប៊ុនច័ន្ទម៉ុល និងអាចារ្យប៊ុន ជាមេ ។ ប៉ែកខាងសៀមរាបមានឈ្មោះ*ដាបឈួនមូលពេជ្រ* ជាមេ ។

ពួកឥស្សរៈទាំងប៉ុន្មាននេះ បានវាយខានទ័ពបារាំងជាច្រើនណាស់ដែរ ។

តែនៅក្នុងចំណោមពួកឥស្សរៈទាំងនោះ, មានមនុស្សម្នាក់ឈ្មោះ*ពុកឆាយ*ធ្វើការឱ្យឈ្មោះ *ម៉ៀងវ៉ាន់ទ្រិញ* ជាយួនយៀក-

មិញ ។ យួននេះចូលមកញ៉ាក់ពុកឆាយឱ្យដើរទៅតាមគំនិតគេ។ ពុកឆាយជាមនុស្សល្ងង់ខ្លៅហើយកាចសាហាវណាស់អាងកាប់, អាងចាក់ ហើយជាអ្នកលេងល្បែងស៊ីសងផង ... ។

មានរឿងមួយ នៅក្នុងមណ្ឌលខ្ញុំ គឺ *ស្រុកល្វាឯម* ខេត្តកណ្ដាល ។ កាលណោះមានមេខ្មែរឥស្សរៈម្នាក់ឈ្មោះ អាចារ្យយី ។ គាត់បានវាយតទល់ជាមួយនឹងពួកយៀកមិញហើយបានសម្លាប់យៀកមិញ អស់ចំនួន ៣៤ នាក់ក្នុងយប់នោះឯង ។ ខាងពួកឥស្សរៈ មានស្លាប់៧នាក់ ។ កន្លែងកើតហេតុ ហៅថា ភូមិ*ថាញ់ថេវ* ស្ថិតនៅចន្លោះ*ឃុំសារិកាកែវ* និងឃុំ *ពាមឧកញ៉ាអុង* ។ ពួកឥស្សរៈដុតផ្ទះយួនចាប់ពី*ឃុំស្វាយជ្រុំ* ទៅឃុំ *អារីយ៍ក្សត្រ-សារិកាកែវ-ពាមឧកញ៉ាអុង-កោះរាស្ត្រ-ថ្មគរ-ផ្លូវត្រី* ក្នុងឃុំទាំងនោះ ផ្ទះយួនមានប៉ុន្មាន ពួកឥស្សរៈដុតចោលទាំងអស់ ។ មូលហេតុឱ្យមានការទាស់គ្នាគឺថា មកពីពួកយៀកមិញបោកយកប្រាក់អំពីខ្មែរឥស្សរៈ ។ ដំបូងពួកយៀកមិញចូលមកសុំរួបរួមគ្នាវាយដេញបារាំងទាំងអស់គ្នា ។ តែពួក អាចារ្យយីមិនសូវមានអាវុធ,យួនក៏និយាយឱ្យអាចារ្យយីរកលុយឱ្យគេ. គេនឹងទៅទិញអាវុធពីទាហានបារាំងនៅព្រៃនគរយកមកឱ្យ ។ អាចារ្យយី ដើររៃប្រាក់ពីអ្នកស្រុកនៅពេលនោះបាន២០ម៉ឺនរៀលប្រកពេញមួយបាវធំប៉ុងណែនប្រគល់ទៅឱ្យពួកយៀកមិញ ។លុះយួនទិញកាំភ្លើងបានមកហើយ. កាំភ្លើងថ្មីៗវាទុកហើយឱ្យអាចាស់ៗទៅអាចារ្យយី ។ អាចារ្យយីដឹងក៏ទៅសួរដេញដោលបណ្ដាលឱ្យមានរឿងទាស់ទែងគ្នាឡើង ។ ពួកអាចារ្យយីក៏ចាប់កាំភ្លើងបានមុនបាញ់រះទៅលើពួកយួនស្លាប់អស់៣៤នាក់. ខាងអាចារ្យយីស្លាប់៧នាក់ ។ ពួកយួនឃើញហេតុការណ៍មិនស្រួលក៏នាំគ្នារត់ទៅកាន់ស្រុកវាវិញអស់ទៅ ។ល។

តមកប្រទេសខ្មែរ បានទទួលរបបគ្រប់គ្រង តាមរបៀប





ប្រជាធិបតេយ្យ.គេបានបង្កើតឱ្យមានការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាជាតិ. មានរដ្ឋាភិបាលចេញពីរដ្ឋសភា ក៏បានតវ៉ាសូមដោះលែងយកខ្មែរជាប់ឃុំទាំងប៉ុន្មានដែលបារាំងចាប់យកទៅឱ្យបានរួចខ្លួនចេញមកវិញទាំងអស់. ឯ ចំណែកលោកសឺងង៉ុកថាញ់នៅជាប់នៅឯស្រុកបារាំងនៅឡើយ ។

កាលបារាំងយល់ព្រមឱ្យខ្មែរគ្រប់គ្រងប្រទេស តាមរបៀបមានរដ្ឋសភាមុនដំបូងខ្មែរទាំងអស់បង្កើតបានគណបក្សចំនួន ៤ គឺ :

- ទី១ គណៈបក្សប្រជាធិបតេយ្យមានរូបក្បាលដំរីជាសញ្ញាមាន *ទ្រង់ស៊ីសុវត្ថិយុត្តិវង្ស* និង *លោកអៀវកើស* ជាអ្នកដឹកនាំ ។
- ទី២ គណៈបក្សសេរីភាព មានទង់ជាតិរូបប្រាសាទជាសញ្ញាមាន *ទ្រង់នរិន្ទដេក* ជាអ្នកដឹកនាំ ។
- ទី៣ គណៈបក្សខេមរៈប៉ុណ្ណការមានរូបនាងគង្ហីងព្រះធរណីជាសញ្ញា. មានទ្រង់ *ស៊ីសុវត្ថិសិរិមតៈ* និង *លោកលន់នល់* ជាអ្នកដឹកនាំ ។
- ទី៤ គណៈបក្សប្រូក្រេស៊ីស មានរូបព្រួញជាសញ្ញា. មាន *ទ្រង់នរោត្តមម៉ុងតាណា* ជាអ្នកដឹកនាំ ។

ការតាំងរដ្ឋសភា. មុនដំបូងមាននិតិកាលតែមួយឆ្នាំសម្រាប់តែងច្បាប់រដ្ឋធម្មនុញ្ញ,រួចហើយត្រូវរំលាយទៅវិញបោះឆ្នោតសារជាថ្មីមានកំណត់និតិកាលចំនួន៤ឆ្នាំទើបអស់អាណត្តិ ។

## តើមរណភាពរបស់ទ្រង់ យុត្តិវង្ស បណ្តាលមកពី រោគាពាធឬមកពីផែនការណ៍?

មុនពេលដែលរដ្ឋសភាបណ្តោះអាសន្នផុតអាណត្តិបីខែ គេបានទទួលសំបុត្រអនាមិកមួយច្បាប់ របស់អ្នកសិក្សាពីស្រុកបារាំងផ្ញើមកជូនរដ្ឋសភាជាតិដែលមានសេចក្តីថា ៖

-មន្ត្រីជាន់ខ្ពស់បារាំងប្រចាំនៅប្រទេសខ្មែរបានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅជូន« លោកធំ» នៃប្រទេសបារាំងថាសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ដែលបារាំងបានរៀបរៀងឱ្យខ្មែរប្រើនោះពុំបានសម្រេចទេ,ខ្មែរបដិសេធចោលទាំងស្រុង,ព្រោះនៅក្នុងចំណោមពួកសមាជិក *គណបក្សប្រជាធិបតេយ្យ* មានមនុស្សសំខាន់មួយរូប ដែលកិច្ចការអ្វីៗគេច្រើនជឿនិងទុកចិត្តលើមនុស្សនោះណាស់ ។ ក្រែងតែរកឧបាយកលកំចាត់មនុស្សនោះឱ្យចេញក្រៅពីសង្គមខ្មែរ ទើបកិច្ចការអ្វីៗអាចសម្រេចទៅបាន។

រឿងសំបុត្រអនាមិកនេះគឺលោក *អៀវ-កើស* ប្រធានរដ្ឋសភាមានប្រសាសន៍ប្រាប់ខ្ញុំ ។

មុនរដ្ឋសភាផុតអណត្តិបីខែ, បារាំងបានអញ្ជើញទ្រង់ *យុត្តិវង្ស* (1) ទៅជប់លៀងនៅសណ្ឋាគាររដ្ឋមួយ ចាប់ពីពេលយប់

(1) *ទ្រង់យុត្តិវង្សជាបុត្រព្រះអង្គម្ចាស់ចំរើនវង្សនិងម្ចាស់ក្សត្រីយ៍ស៊ីសុវត្ថិយុត្តិផានប្រសូត្រនៅឆ្នាំ ១៩១៣។ ប្រឡងជាប់សញ្ញាប័ត្របណ្ឌិតរដ្ឋផ្នែកគណិតសាស្ត្រនៃមហាវិទ្យាល័យម៉ុងប៉េល្យេនៃប្រទេសបារាំង នៅឆ្នាំ១៩៤១.ក្នុងជន្មាយុ២៨វស្សា (Docteur d'Etat ès-sciences Mathématiques à montpellier France ) ។ នៅខែឧសភាឆ្នាំ១៩៤៧.ទ្រង់បានកសាងគណបក្សមួយឈ្មោះ គណបក្សប្រជាធិបតេយ្យ ជាមួយមិត្តភក្តិដែលមានលោក អៀវកើស ជាដើម ។*





ទៅទល់ភ្លឺ ។ លុះព្រឹកឡើងទ្រង់ យុត្តិវង្ស ពុំបានទៅកាន់ទីស្នាក់ការការិយាល័យទេ ព្រោះក្នុងថ្ងៃនោះលោកឈឺ ។ លោកយាងទៅ ព្យាបាលព្រះអង្គនៅមន្ទីរពេទ្យ *ព្រះកេតុមាលា* ។ លោកឱ្យគេព្យាបាលនៅមន្ទីរពេទ្យបានតែ៩ថ្ងៃប៉ុណ្ណោះ ក៏បានទទួលអនិច្ចកម្មទៅ ។ មតិពីរផ្នែកបានកើតឡើង ៖

-មួយ ថាលោកសុគត ដោយរោគាពាធ ព្រោះលោកមានជម្ងឺសួតក្អករបេង ជាយូរយារមកហើយ ។

-មតិមួយទៀតថា លោកសុគតនេះគឺនៅក្នុងផែនការណ៍របស់គេទេ ព្រោះតាមធម្មតា បើស្លាប់និងជម្ងឺសួតគឺមិនមែនឈឺតែ៩ថ្ងៃហើយស្លាប់នោះទេ។ តាមដែលគេធ្លាប់ចំណាំមក,មុននឹងស្លាប់ត្រូវប្រើពេលជាច្រើនខែឬជាច្រើនឆ្នាំផងទើបស្លាប់ ។ តែនេះគ្រូននៅពេទ្យតែ៩ថ្ងៃក៏សុគតយ៉ាងនេះ, មិនគួរសោះ ។

<u>ដល់និតិកាលទី២មានកំណត់៤ឆ្នាំ</u> ៖

តមកលោក អៀវ-កើស អ្នកដឹកនាំគណបក្សប្រជាធិ-បតេយ្យ ត្រូវមានការជ្រើសតាំងសមាជិករដ្ឋសភាជាស្ថាពរសម្រាប់អនុវត្តច្បាប់រដ្ឋធម្មនុញ្ញតទៅ ដែលមានអាយុសភា៤ឆ្នាំទើបផុតអាណត្តិ ។ និតិកាលនេះគេរៀបចំមណ្ឌលថែមទៅជា ៨-៩ មណ្ឌល ដែលមានគណបក្ស៤ចេញមកបង្ហាញឱ្យរាស្ត្រជ្រើសតាំង គឺ ៖

-គណបក្សប្រជាធិបតេយ្យ

-គណបក្សសេរីភាព

-គណបក្សខេមរៈបុណ្ណការ និង

-គណបក្សប្រូក្រេស៊ីស្ត៍ (Progressiste) ។

ផលនៃការបោះឆ្នោតលើកនោះគឺ ៖

-គណបក្សប្រជាធិបតេយ្យ បាន ៥៩ កៅអី

-គណបក្សសេរីភាព បាន ២៨ កៅអី

-គណបក្សខេមរៈបុណ្ណការ បាន ២ កៅអី

-គណបក្សប្រូក្រេះស៊ីស្ត៍ បាន ០ កៅអី

គ្រានោះលោក អៀវ-កើស ធ្វើជាប្រធានរដ្ឋសភា. លោក *ឈាន-វៃម* ជានាយករដ្ឋមន្ត្រី ។ គណរដ្ឋមន្ត្រីនៃលោក ឈាន-វៃម ប្រតិបត្តិការមិនបានយូរប៉ុន្មានទេ ។ បន្តិចក្រោយមក លោក ឈាន-វៃម ក៏លាឈប់ពីដំណែង ។ ការលាឈប់ពីដំណែងនេះ. តាមដែលខ្ញុំដឹង គឺមកពីមានការមិនចុះសម្រុងគ្នារវាងសមាជិកនៃគណបក្ស ក្នុងការដែលលោក ឈាន-វៃម សូមដកអភ័យឯកសិទ្ធិពីដំណាងរាស្ត្រពុករលួយខ្លះជូនទៅតុលាការឱ្យជំនុំជំរះ ពីបទកែបន្ទំ យកឈ្មោះរាស្ត្រ ទៅសុំបើកយកអំបោះលក់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ។ មានដំណាងរាស្ត្រខ្លះទៀតមានការអាក់អន់ចិត្តដោយគេពុំបានបញ្ចូលខ្លួនទៅក្នុងគណរដ្ឋ-មន្ត្រីនេះ ។ម្ល៉ោះហើយទេះតែមានការរកាំរកូសក្នុងរដ្ឋសភា ។ ដោយយល់ហេតុនេះទើបលោក ឈាន-វៃម បានសម្រេចចិត្តសូមលាលែងចេញពីគណរដ្ឋមន្ត្រីរបស់លោកទាំងអស់ ។

តមក សភាចាត់តាំងឯកឧត្តម *ប៉ែន-នុត* ឱ្យជ្រើសរើសគណរដ្ឋមន្ត្រីសារជាថ្មី ។ រដ្ឋាភិបាល ឯកឧត្តមប៉ែន-នុតមានការពិបាកយ៉ាងខ្លាំង ព្រោះក្នុងការជ្រើសរើសរដ្ឋមន្ត្រីក្រសួង





យុត្តិធម៌ (តុលាការ)មានបេក្ខជនពីររូបគឺឯកឧត្តម *មាស-សាឯម* និង ឯកឧត្តម *យ៉ែម-សំបូរ* ។ ដោយសភាមិនពេញចិត្តនិងលោក យ៉ែម-សំបូរ. គេក៏ជ្រើសរើសលោក មាស-សាឯមជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលធ្វើឱ្យលោក យ៉ែម-សំបូរ មានការអាក់អន់ចិត្តយ៉ាងខ្លាំង ព្រោះក្នុងការជ្រើសរើសគណរដ្ឋមន្ត្រីទាំងពីរលើកនេះ លោកពុំដែលបានចូលនិងគេសោះក៏កើតមានការមិនសប្បាយចិត្ត ។ រដ្ឋាភិបាល លោក ប៉ែន-នុត ប្រតិបត្តិការមិនបានយូរប៉ុន្មាន ត្រូវសភាទំលាក់ចេញទៀត ដោយសាររឿង រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ *មៀច-គន្ធ* បានយល់ព្រមឱ្យមេសៃវៀនឈ្មោះ *គី-ហេង* បិទទន្លេកំពង់ឆ្នាំងមួយចំហៀងត្រង់ម្តុំ *ភូមិខ្នាត្រហឹម* ធ្វើឱ្យត្រីងាប់អណ្តែតពាសពេញទន្លេកំពង់ឆ្នាំង ចុះមកដល់ក្រុងភ្នំពេញ ។ លុះរដ្ឋាភិបាល ប៉ែន-នុត ធ្លាក់ហើយ,គេឃើញ លោកយ៉ែម-សំបូរ ចេញចូលគាល់ព្រះមហាក្សត្រីយានី ជាញឹកញាប់ ... ។

ពេលនោះក៏លេចឮពាក្យចចាមរ៉ាមដ៏អកុសលចេញមកថា លោកអៀវ-កើស ចង់បំបាត់របប *រាជានិយម* ដើម្បីធ្វើជា *សាធារណរដ្ឋ* វិញ ។ (ត្រង់នេះអ្នកនិពន្ធខ្ញុំ សូមបញ្ជាក់ថាលោកអៀវ-កើស ដែលខ្ញុំស្គាល់ច្បាស់ ហើយដែលមានការស្និតស្នាលធ្លាប់ធ្វើការយ៉ាងជិតស្និតជាមួយគ្នា. គ្មានគំនិតបែបនេះទេ ។លោកអៀវ-កើស មានចិត្តស្មោះត្រង់និងព្រះមហាក្សត្ររបស់ខ្លួន ។ រីឯសមាជិកសភាទាំងប៉ុន្មានមានការគោរពជឿទុកចិត្តលើលោកស្មើរតែទាំងអស់គ្នាក្នុងសភាទាំងមូលទៀត )។

តាមការសន្និដ្ឋានរបស់អ្នកនិពន្ធខ្ញុំ គឺថា ប្រហែលជាមាន

មនុស្សអកុសលបង្កើត *ពាក្យអពមង្គល,ចាក់រុក* ដើម្បីទៅផ្តាប់ផ្តុនផ្លូវយកបុណ្យស័ក្តិក៏មិនដឹង ?

ក្រោយដែលរដ្ឋាភិបាល ប៉ែន-នុត ធ្លាក់ទៅ,ព្រះករុណា *នរោត្តមសីហនុ* ក៏ចាត់តាំង លោកយ៉ែម-សំបូរ ជូនមករដ្ឋសភាឱ្យ *រៀបចំរដ្ឋាភិបាល* បន្តពីលោក ប៉ែន-នុត ទៅទៀត ។

គ្រង់នេះសមាជិករដ្ឋសភាទាំងអស់ប្រឆាំងនិងព្រះបញ្ជានេះ មិនព្រមបោះឆ្នោតឱ្យលោក យ៉ែម-សំបូរ ស្ទើរតែទាំងអស់គ្នា ព្រោះគេយល់ថាលោក យ៉ែម-សំបូរ ខ្វះសមត្ថភាពមិនអាចទទួលឱ្យធ្វើជា *នាយករដ្ឋមន្ត្រី* បានទេ តែគេសុខចិត្តឱ្យធ្វើបានត្រឹមតែសមាជិករដ្ឋាភិបាលខាងតុលាការតែប៉ុណ្ណោះ (ព្រោះគេយល់ថា *និស្ស័យចិត្តថ្លើមលោកជាអ្នកកាចសាហាវ* ទៀតផង)។ នៅពេលដែលខ្ញុំដឹងថា សមាជិករដ្ឋសភា មិនព្រមបោះឆ្នោតឱ្យលោក យ៉ែម-សំបូរ, ខ្ញុំក៏ចូលទៅជំរាបលោក អៀវ-កើស ថា រឿងព្រះមហាក្សត្រចាត់តាំងលោក យ៉ែម-សំបូរ នេះមើលទៅមិនអាចសម្រេចទេព្រោះសមាជិកទាំងអស់ មិនយល់ព្រមបោះឆ្នោតឱ្យ ។ លុះលោក អៀវ-កើស ជ្រាបតាមសេចក្តីដែលខ្ញុំប្រាប់ហើយ លោកក៏អញ្ជើញសមាជិករដ្ឋសភាទាំងអស់ចូលប្រជុំក្នុងបន្ទប់សម្ងាត់ពិសេសមួយ ។ លោក អៀវ-កើស ចាប់ផ្តើមសួរសមាជិកសភាទាំងអស់ពីរឿងព្រះករុណាចាត់តាំងលោក យ៉ែម-សំបូរ ធ្វើជានាយករដ្ឋមន្ត្រី តើអស់លោកយល់យ៉ាងដូចម្តេច ? សមាជិកសភាឆ្លើយជំរាបលោក អៀវ-កើស វិញ ដោយមានហេតុបីយ៉ាង ៖

-ទី១ លោក យ៉ែម-សំបូរ មិនសូវយល់ខាងសេដ្ឋកិច្ច





និងហិរញ្ញវត្ថុ ។

-ទី២ លោកមាននិស្ស័យកាចឆេវឆាវ កាលបើគាត់និយាយមិនឈ្នះគេ គាត់ច្រើនតែហៅគេឱ្យប្រដាល់គ្នា ។

-ទី៣ គាត់មិនសូវស្តាប់គេក្រៅអំពីយោបល់របស់គាត់នោះថែមទៀតផង ។

លោក អៀវ-កើស ស្តាប់ចម្លើយរបស់សមាជិករដ្ឋសភារួចហើយ លោកក៏មាន ប្រសាសន៍ពន្យល់សភាវិញថា ៖

*-បើយើងមិនព្រមអនុម័តតាមព្រះវិរិះ ដែលព្រះករុណាបានតែងតាំងហើយនោះទេ នោះឈ្មោះថា យើងនិងព្រះមហាក្សត្រ មានទំនាស់និងគ្នា ។ ពេលនេះយើងប្រឆាំងមិនបានទេ ព្រោះរាស្ត្រភាគច្រើននៅមានជំនឿលើព្រះមហាក្សត្រ ។ ដូច្នេះគួរយើងសម្រួលព្រះរាជហឫទ័យព្រះអង្គផងទៅ បើយើងមានទំនាស់និងស្តេច,យើងមិនអាចធ្វើអ្វីតទៅទៀតបានឡើយ។*

គ្រានោះសភាយល់ព្រមតាមលោកប្រធាន អៀវ-កើស តែគេបោះឆ្នោតឱ្យលោក យ៉ែម-សំបូរ ល្មមតែធ្វើការបានតែប៉ុណ្ណោះ គេមិនឱ្យច្រើនតាមចំនួនរដ្ឋសភាមាននោះទេ ។

លុះដល់លោក យ៉ែម-សំបូរ ឡើងកាន់អំណាច លោកគ្មានគិតអ្វីក្រៅអំពីបង្កើតបនល្បែងភ្នាល់ទេ ។ លោកបានចូលមកពិគ្រោះនិងលោកប្រធាន អៀវ-កើស សូម *បើកលេងល្បែងកាស៊ីណូ* នៅចំកណ្តាលក្រុងត្រង់វាលផ្សារកណ្តាល ។ លោក អៀវ-កើស ប្រកែកមិនយល់ព្រមជាដាច់ខាត ។ កន្លងមកប្រហែលជាមួយអាទិត្យ,ថៅកែ *ឡុង-ហៃ* និងថៅកែ*ឈុន-ស្រេង* មកពីងខ្ញុំឱ្យជូនទៅផ្ទះលោក អៀវ-កើស ។ ខ្ញុំប្រកែកមិនជូន

ទៅទេ.ព្រោះលោក អៀវ-កើស មិនទទួលភ្ញៀវនៅផ្ទះទេ.លោកទទួលបានតែនៅប៊ុយរ៉ូរដ្ឋសភាតែប៉ុណ្ណោះ ។ រឿងបើកកាស៊ីណូនេះក៏ស្ងាត់បាត់អស់មួយរយៈទៅ ។ ក្រោយមកលោក យ៉ែម-សំបូរទៅបង្ខំឱ្យរដ្ឋសភាអនុម័តលើថវិកា សូមបើកមុខចំណាយ។

ដោយសេចក្ដីគ្រោងប្រាក់ចំណាយរបស់ក្រសួងផ្សេងៗ ទើបតែនិងបញ្ជូនទៅឱ្យរដ្ឋសភាបានមួយអាទិត្យ សភាមិនទាន់បានពិនិត្យសព្វគ្រប់នៅឡើយទេ ព្រោះថាការពិនិត្យ ថវិកាបើកមុខចំណាយទាំង១២ក្រសួងត្រូវប្រើពេលយ៉ាងឆាប់ណាស់ក៏មួយខែដែរ ។ ដូច្នេះការបង្ខំឱ្យរដ្ឋសភាអនុម័តលើថវិកាបើកមុខចំណាយក្នុងរយៈពេលមួយអាទិត្យឃើញថាប្រញាប់ពេក មិនអាចធ្វើការពិនិត្យបានឡើយ ។ ត្រង់នេះហើយ ដែលលោក យ៉ែម-សំបូរ យល់ថា សភាមិនធ្វើការ. សភាធ្វើបាបលោក។ លោក យ៉ែម-សំបូរ ក៏ចូលទៅទូលព្រះករុណា សុំរំលាយរដ្ឋ-សភាចោល ។ ព្រះករុណាយល់ព្រមតាមលោកយ៉ែម-សំបូរទូល ក៏សម្រេចចេញព្រះរាជក្រឹត្យឱ្យរំលាយ សភាក្នុងឆ្នាំ១៩៥០នោះទៅ ។

ការដែលសភាធ្វើការប្រឹតប្រៀងយ៉ាងនេះធ្វើឱ្យអ្នករដ្ឋ-ការខ្លះ មិនពេញចិត្តនិងរដ្ឋសភាទេ ។ *ក្នុងគ្រាព្រះករុណា*

---

*ការពិនិត្យថវិការក្នុងសម័យមានរដ្ឋសភា. សូមអ្នកអានជ្រាបថាគេពុំមែនធ្វើលេងៗទេ ។ ទេគេត្រូវអញ្ជើញចៅក្រសួងនីមួយៗមកសួរដេញដោលអំពីមុខរបស់ដែលត្រូវចាយ គឺចាយទៅលើមុខរបស់អ្វីជាគ្រឿងចាំបាច់ឬទេ ? មានក្រសួងខ្លះគ្រោងប្រាក់សូមបើកមុខចំណាយដាក់ឱ្យលើសដល់ទៅ បីភាគ លើរបស់ដែលត្រូវចាយតែ ពីរភាគប៉ុណ្ណោះក៏សឹងមាន ។ ឯសមាជិកគណកម្មាការសម្រាប់ពិនិត្យថវិការ ក្នុងជំនាន់លោកអៀវ-កើស. លោករើសយកច្រើនតែអ្នកជំនួញ ដូចជា លោកហាក់ម៉ុងហេង.អ៊ិតសាប.អ៊ិតសាម.សំញាន.ចេងសន.ឃិនដៃ.ពុនថាន់.ប៉ែនអន.ចេងសន ទាំងអស់មាន១២នាក់ខ្ញុំភ្លេចឈ្មោះបីនាក់ទៀត ពុំបានចាំ ។*





*រំលាយរដ្ឋសភាម្ដងៗ មានអ្នកខ្លះក្រេកអរហើរកញ្ច្រៀវទះដៃថែមទៀតផង* ។ ត្រូវនិងពាក្យព្រេងមួយឃ្លាថា ៖

«ខឹងនិងសង្កើចទៅដុតមុងចោល»!

ចំណែករដ្ឋាភិបាលយ៉ែម-សំបូរវិញ ក្រោយរំលាយរដ្ឋសភាបានប្រហែលជាមួយខែតែប៉ុណ្ណោះ ក៏ចាប់បើកលេងល្បែង កាស៊ីណូនៅ *វាលផ្សារកណ្ដាល* ខាងជើង វត្តឧណ្ណាលោម យ៉ាងគគ្រឹកគគ្រេង ។ លុះកូនសិស្សអ្នកសិក្សាយល់ឃើញនូវអំពើនេះមិនល្អ.ក៏នាំគ្នាធ្វើបាតុកម្មហែក្បួនតាមអតីតផ្លូវ «អូរីយ៉េ» កាត់មករកហ្វូងល្បែងកាស៊ីណូត្រង់វាល «ផ្សារកណ្ដាល»។

រដ្ឋាភិបាលយល់ឃើញហេតុមិនស្រួលក៏បញ្ជាឱ្យរទេះឡានបាញ់ទឹកកាត់ហ្វូងបាតុករឱ្យរត់ខ្ចាត់ខ្ចាយអស់ទៅ ។ ក្នុងក្បួនហែនោះ. បាតុករស្រែកទ្រហឹងអ៊ឹងអាប់.មានភ្លេង ឆៃយ៉ាំ ឡុកនាំដើរមុខក្បួន រួចគេស្រែកច្រៀងជាពាក្យស្លោកថា ៖

«មាសសាឯម  យ៉ែមសំបូរ
បើកកាស៊ីណូ  បិទវិទ្យាល័យ  រំលាយសភា !»

*រួចគេស្រែកបន្ទរថា* :

«ហ៊ុយម៉ោង-ហ៊ុយម៉ោង ! »

នេះជាពាក្យច្រៀងចំអកឡកឡឺយ របស់ កូនសិស្សអ្នកសិក្សា ឱ្យដល់ឈ្មោះរដ្ឋមន្ត្រីទាំងបីរូប មានលោកយ៉ែម-សំបូរជានាយករដ្ឋមន្ត្រី.លោកមាស-សាឯម ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោក ហ៊ុយ-ម៉ោង ជារដ្ឋមន្ត្រីការពារប្រទេស ។

លោក យ៉ែម-សំបូរ ខឹងនិងពាក្យស្លោកខ្លាំងពេកក៏បញ្ជាឱ្យគេបិទសាលាវិទ្យាល័យបង្អត់អាហារកូនសិស្សឱ្យប៉ូលីសយាម

ជុំវិញសាលា មិនឱ្យសិស្សដើរចេញចូលបាន ។ ចំណែកពួកកូនសិស្សនៅខាងក្រៅ ក៏នាំគ្នារៃលុយទិញនំប៉័ងយកទៅបោះចូលទៅក្នុងសាលា ។ ក្នុងរយៈ៥ថ្ងៃ ដែលគេបិទសាលា, គេឮសូរតែសម្លេងស្លូរថៃយ៉ាំ និង សម្លេងច្រៀងពាក្យស្លោក ៖

មាសសាងម-យ៉ែមសំបូរ-បើកកាសិណ្ឌបិទវិទ្យាល័យ ...

រំលាយសភា, ហ៊ុយម៉ោង,ហ៊ុយម៉ោង ! ជារឿងរាល់យប់-ថ្ងៃគ្មានលោះថ្ងៃណាឡើយ ...

តមកព្រះករុណា នរោត្តម-សីហនុ ទ្រង់យាងទៅស្រុកបារាំង ។ ព្រះអង្គទ្រង់អញ្ជើញលោក អៀវ-កើស ឱ្យតាមហែព្រះអង្គទៅជាមួយដែរ ។ លោក អៀវ-កើស អត់លុយមកខ្ចីប្រាក់ពីខ្ញុំ បីម៉ឺនរៀល ដើម្បីយកទៅកុម្មង់រថយន្តម៉ាកស៊ីត្រូអែនមកប្រើ ។ លោកទៅដល់ស្រុកបារាំង, លោកផ្ញើកាតប៉ុស្តាល់រូបប្រាសាទប៉ង់តេអុង ដែលជាកន្លែងកប់ខ្មោចអ្នកប្រាជ្ញ ដាក់សេចក្តីយ៉ាងខ្លីលើសន្លឹកកាត សួរសុខទុក្ខ ហើយថាលោកនឹងវិលត្រឡប់មកស្រុកវិញក្នុងពេលឆាប់ៗនេះហើយ ។ ក្រោយដែលខ្ញុំទទួលកាតប៉ុស្តាល់ពីរឬបីថ្ងៃប៉ុណ្ណោះ លេចឃើញលោក អៀវ-កើស មកដល់ភ្នំពេញដែរ ដោយយកស្ទីឡូមួយមកឱ្យខ្ញុំ ។ ខ្ញុំក៏សួរថា ៖

-ម៉េចក៏លោកប្រញាប់មកវិញម្ល៉េះ ?

លោកឆ្លើយថា ៖





-ខ្ញុំគ្មានលុយចាយទេ, សម្តេចលោកចេញតែថ្លៃកប៉ាល់ហោះឱ្យតែប៉ុណ្ណោះ ។ ឯថ្លៃសណ្ឋាគារនិងថ្លៃចាយទឹកត្រូវយើងចេញខ្លួនឯង ។ ខ្ញុំទ្រាំនៅមិនបាន ព្រោះគ្មានលុយ ។ លុយដែលខ្ញុំខ្ចីពីលោកទៅខ្ញុំយកទៅកក់ថ្លៃឡានអស់ហើយ ។

លោកមានប្រសាសន៍ប្រាប់ខ្ញុំថា ៖

-ថ្ងៃសៅរ៍ខាងមុខនេះយើងប្រជុំគ្នារៀបចំធ្វើផែនការណ៍បោះឆ្នោត ព្រោះនៅតែបីបួនខែទៀតយើងត្រូវបោះឆ្នោត សារជាថ្មីទៀតហើយ ។

# អានុស្សាវរីយ៍ដ៏ជូរចត់មួយ ដែលមិនអាចបំភ្លេចបាន

លុះដល់ថ្ងៃសៅរ៍ឆ្នាំ១៩៥០ (ខ្ញុំមិនចាំថ្ងៃ-ខែ (1)) លោក *អៀវ-កើស* អញ្ជើញសមាជិកគណកម្មការនាយកនៃគណបក្សទាំងអស់ទៅប្រជុំនៅទីចាត់ការ គណបក្សប្រជាធិបតេយ្យ នៅផ្លូវទល់មុខផ្ទះរេស៊ីដង់ម៉ែរ (Résident maire) នៅភ្នំពេញ ។

គ្រានោះគណកម្មាការនាយក ព្រមទាំងសមាជិកធម្មតាអញ្ជើញទៅប្រជុំមានគ្នាច្រើនគ្រាន់បើរដែរ ។ ចំណែកខ្ញុំ និងលោក *មិញ-ណាគ្រី* ទៅទទួលទានការពុំបានទៅប្រជុំនាថ្ងៃនោះទេ ។ លុះប្រជុំចប់សព្វគ្រប់ហើយ ពេលម៉ោងប្រហែលជា៨យប់ ពួកសមាជិកដែលមកប្រជុំទាំងប៉ុន្មានក៏ចេញទៅផ្ទះអស់ហើយនៅតែលោកអៀវ-កើសនិងលោក*ម៉ែត-ហ៊ាន*អង្គុយជជែកគ្នាបន្តទៅទៀត ។ស្រាប់តែ !... នៅម៉ោងប្រហែល៨យប់ សម្លេងគ្រាប់បែកមួយគ្រាប់ផ្ទុះឮទៅដល់កន្លែងដែលខ្ញុំកំពុងតែអង្គុយទទួលទានភោជនាហារពេលមង្គលការ ។ ក្រោយដែលបានឮស្នូរសម្លេងនោះប្រហែលពីរនាទីមកប៉ុណ្ណោះ ក្មេងនៅផ្ទះខ្ញុំជិះកង់នាំដំណឹងនេះមកប្រាប់ ។ ខ្ញុំនិងលោកមិញ-ណាគ្រី ទាំងពីរនាក់ពុំបានទទួលទានអាហារនិងគេទេ ។ យើងចងដៃគេហើយក៏ប្រញាប់ប្រញាល់មកកាន់កន្លែងដែលកើតហេតុភ្លាម។ លោកអៀវ-កើសដួលទៅនិងថ្នៃអិដ្ឋ.ចំណែកឯលោក ម៉ែត-ហ៊ាន ត្រូវបាក់ជើងខាងឆ្វេង ។ លោកនៅមានស្មារតីក៏ស្រែកហៅ

(1) *តាមឯកសារខ្លះសរសេរថា នៅថ្ងៃ ១៤-មករា-១៩៥០*





ឱ្យគេជួយ ។ លោកនិយាយថា :

-មានគេបោះគ្រាប់បែកមួយគ្រាប់ចូលមកក្រោមតុអង្គុយប្រជុំនោះ ។ គ្រាប់បែកផ្ទុះឡើងត្រូវចំពោះលោកអៀវកើស។ លុះមនុស្សផ្អើលទៅមើលឃើញ គេក៏ដឹកលោកទាំងពីរនាក់ទៅកាន់មន្ទីរពេទ្យព្រះកេតុមាលា ។ លោកអៀវ-កើស ដាច់ខ្យល់ស្លាប់នៅមន្ទីរពេទ្យនោះទៅ ... ។

ឯចំណែកឃាតករបោះគ្រាប់បែកនោះមានឈ្មោះ *ស៊ុក* ត្រូវជាកូនលោកអុងតាំង *ស៊ុន-ហួរ* ។ គេចាប់វាបានយកទៅប្រគល់ឱ្យប៉ូលីស ។ នៅពេលនោះលោក *អ៊ុក-ស៊ុន* ត្រូវជាប្អូនថ្លៃ លោកយ៉ែម-សំបួរ ធ្វើជាអធិបតីក្រុមប៉ូលិសសន្តិសុខជាតិ។ លោកនេះប្រើបម្រើឱ្យមកយកឃាតករ «ទៅឃុំ »នៅកន្លែងប៉ូលិសសម្ងាត់បាត់ទៅ ?!?

តាមចំឡើយរបស់ឃាតករ នៅស្នងការដ្ឋានប៉ូលិស. លើកដំបូងវាបន្ទំថា វាឈ្មោះ «នួយ៉ា» ។ វាថានិយាយថា វាបាន «ស៊ីឈ្នួល» មនុស្សម្នាក់ទៀតនៅឃុំកំបូល ឱ្យវាយកគ្រាប់បែកមកបោះសម្លាប់លោក អៀវ-កើស ។ តែចំណែកអ្នកនៅឃុំកំបូលនោះ«គេ»នាំវាយកទៅសម្លាប់នៅព្រៃក្រោយ *វត្តកំបូល* ចោលរួចទៅហើយ ។ កន្លែងដែលគេសម្លាប់វានោះមានចម្ងាយពីវត្តប្រមាណជា មួយរយម៉ែត្រ តែប៉ុណ្ណោះ ... ។

& &
&

លោក អៀវ-កើស មានប្រជាប្រិយភាពណាស់ ។ គេដំកល់សពលោកទុកនៅផ្ទះស្អិតនៅខាងត្បូង *វត្តកាកែវ* ធ្វើបុណ្យជាច្រើនថ្ងៃ ។

ក្នុងពេលក្បួនដង្ហែសពយកទៅបូជា មានមនុស្សទៅចូលរួមជាច្រើនកុះករ ។ មនុស្សដើរជាក្បួនដង្ហែមានប្រវែងប្រមាណជាពីរឬបីរយម៉ែត្រ ។ លុះរួចរាល់បុណ្យសពលោក ហើយប្រមាណជាបីឬបួនខែ លោកស្រី អៀវ-កើសបានយកប្រាក់ទៅសងខ្ញុំវិញតាមចំនួនដែលប្ដីលោកស្រីជំពាក់ ។





បន្ទាប់ពីមរណភាពរបស់ លោកអៀវ-កើស ដោយការព្យាបាទនេះមក, លោក *ហ៊ុយ-កន្ធុល* និងលោក *យូទ-ផៃណា*រៀបចំដឹកនាំគណបក្ស ប្រជាធិបតេយ្យ តទៅទៀត ។

ក្នុងពេលបោះឆ្នោតលើកទី៣ ត្រូវមានគណបក្សដល់ទៅប្រាំពីរ គឺ ៖

-បក្សលោកយ៉ែម-សំបូរ ១

-បក្សលោកសំ-ញាន ១

-បក្សលោកម៉ៅ-ចយ ១

បក្សទាំងបីនេះគឺបែកចេញអំពីរគណបក្សប្រជាធិបតេយ្យទាំងអស់ព្រោះមិនព្រមគោរពតាមវិន័យគណបក្សបានលាចេញទៅរួមគ្នាករបង្កើតគណបក្សមួយទៀត ។ លុះករបង្កើតបានហើយក៏មានការឈ្លោះទាស់ទែងគ្នាអំពីដណ្ដើមធ្វើមេដឹកនាំគណបក្សពុំបានសម្រេចក៏តាំងចេញមុខករបង្កើតបក្សតែរៀងខ្លួន ។ បក្សលោក យ៉ែម-សំបូរ យករូប ហនុមានលីផែនដី បក្សលោកសំ-ញាន យករូបកណ្ដាប់ស្រូវជាសញ្ញា បក្សលោកម៉ៅ-ចយគេឱ្យឈ្មោះថា បក្សវៀសាន្តមានជ័យ មិនដឹងយករូបអ្វីធ្វើជាសញ្ញាទេ ព្រោះមិនចាំ ។ល។

ឯផលនៃការបោះឆ្នោតក្នុងគ្រានោះបក្សប្រជាធិបតេយ្យបាន៥៣កៅអី, សេរីភាព២៩កៅអី, ខេមរប៉ុណ្ណការ២កៅអី, បក្សប្រូក្រេស៊ិះ, បក្សលោកយ៉ែម-សំបូរ, បក្សលោកសំ-ញាន និងបក្សលោកម៉ៅ-ចយ ឥតបានកៅអីទេ ។

ក្នុងនិតិកាលលើកទីបីនេះអ្នកនិពន្ធចាំមិនច្បាស់, ឃើញលោក *យូទ-ផៃណា* ធ្វើប្រធានសភាម្ដង, ឃើញលោក*យ៉ិក-ស៊ែន*

ធ្វើម្តង.តែក្នុងពេលនោះមិនដឹងលោកណាធ្វើជានាយករដ្ឋមន្ត្រីខ្លះក្នុងសម័យលោក ទាំងពីរនេះទេ ។ នៅចុងនិតិកាលនេះ, សម្តេចសីហនុ បានរំលាយសភាចោល ។ លោក *សឺន-សាន* ធ្វើប្រធាន.លោក *ហ៊ុយ-កន្ធុល* ធ្វើជានាយករដ្ឋមន្ត្រី ។

នៅពេលនោះ, គេមិនគ្រាន់តែរំលាយសភាចោលប៉ុណ្ណោះទេ, គេថែមទាំងចាប់សមាជិកសភាចំនួន៩នាក់ យកទៅដាក់គុកដោយគ្មានពិចារណាឱ្យដឹងខុសត្រូវអ្វីថែមទៀតផង ។

លោក *ប៊ូ-ហ៊ីង* បញ្ជាទៅលោក *ឯក-យីអ៊ុន* ឱ្យប្រាប់សមាជិកសភាដែលគេត្រូវចាប់ឱ្យធ្វើពាក្យសូមទោស ។ តែអ្នកដំណាងរាស្ត្រដែលត្រូវគេចាប់ទាំងប៉ុន្មានមិនព្រមសូមទោសទេ. ព្រោះគេយល់ថាខ្លួនគេគ្មានខុសអ្វីទាំងអស់ ។

លុះរំលាយសភាក្នុងអាណត្តិនិតិកាលទីបីរួចហើយគេដាក់សមាជិកសភានេះទៅជាក្រុមប្រឹក្សាជាតិវិញ ។ លោក *ឯក-យីអ៊ុន* ធ្វើប្រធានអង្គការនេះ ។តាមយោបល់អ្នកនិពន្ធខ្ញុំ ឃើញថាអង្គការក្រុមប្រឹក្សាជាតិដែលសម្តេចសីហនុបង្កើតឡើងនេះហាក់បីដូចជា គ្មានប្រយោជន៍អ្វីដល់ជាតិផងទេគ្រាន់តែជាគ្រឿងលួងចិត្តដល់អ្នកដំណាងរាស្ត្រដែលរាស្ត្របានជ្រើសតាំងមកតែប៉ុណ្ណោះ ព្រោះថាអង្គការនេះគ្មានសិទ្ធិអ្វីទាំងអស់ក្នុងការត្រួតពិនិត្យកិច្ចការរដ្ឋដែលរដ្ឋាភិបាលអនុវត្តទាំងប៉ុន្មាននោះ ។

ដោយយល់ថាអង្គការនេះគ្មានសិទ្ធិតែងច្បាប់ឬស្នើច្បាប់មិនឱ្យធ្វើសំនួរដេញដោលរាជរដ្ឋាភិបាល គេធ្វើអ្វីៗស្រេចតែចិត្តគេ ។ បើអង្គការនេះចង់ធ្វើអ្វីត្រូវធ្វើជាសំណូមពរសូមទៅរាជរដ្ឋាភិបាលបើគេយល់ព្រមក៏បាន.គេមិនយល់ព្រមក៏បាន ។ឃើញ





ថាអង្គការក្រុមប្រឹក្សាជាតិនេះគ្រាន់តែចាំអនុម័តច្បាប់អ្វីដែលរាជរដ្ឋាភិបាលដាក់មកឱ្យអនុម័តហើយទទួលខុសត្រូវជាមួយនិងរដ្ឋាភិបាលតែប៉ុណ្ណោះ ។

តមក ហ្លួងសីហនុ បានចាត់តាំងសម្តេច ប៉ែន-នុត ឱ្យបង្កើត «រដ្ឋាភិបាលស្រោចស្រង់ជាតិ » ។

រដ្ឋាភិបាលស្រោចស្រង់ជាតិកើតឡើងក៏គ្មានអ្វីខុសប្លែកពីរដ្ឋាភិបាលមុនៗនោះទេ ។ ចរិការដ្ឋចេះតែជុនដាបទៅៗជាលំដាប់ ។

ក្នុងពេលដែលរដ្ឋាភិបាលប៉ែន-នុត ចាប់ប្រតិបត្តការ, ហ្លួងសីហនុ ទ្រង់លាចាករាជបល្ល័ង្កចូលធ្វើនយោបាយដើម្បីឱ្យស្របតាមមាត្រារដ្ឋធម្មនុញ្ញជាតិដែលហាមមិនឱ្យស្តេច ធ្វើនយោបាយនេះ ។ ព្រះអង្គលើករាជសម្បត្តិនេះថ្វាយទៅព្រះបិតា,ព្រះបាទសុរាម្រិត.ឱ្យទទួលរាជមត៌កតវង្សពីព្រះរាជបុត្របញ្ច្រាសឡើងទៅលើវិញដែលអ្នកនិពន្ធខ្ញុំមិនដែលជួបប្រទះឃើញដល់ម្តងណាឡើយដែលថាឪពុកទទួលមត៌កពីកូន ធ្លាប់ឃើញតែកូនទទួលមត៌កពីឪពុកឬម្តាយតែប៉ុណ្ណោះ ។

លុះព្រះអង្គចាប់ធ្វើនយោបាយ, មុនដំបូងគណបក្សខ្លះបានបញ្ឈប់នូវសកម្មភាពរបស់ខ្លួនរត់ចូលទៅសាកខាងគណបក្សសង្គមរាស្ត្រនិយមទាំងអស់ នៅសល់តែគណបក្សប្រជាធិប-តេយ្យមួយប៉ុណ្ណោះ ដែលហ៊ានតតាំងនិងគណបក្សសង្គមរាស្ត្រនិយម ។ អ្នកដែលរត់ចូល គណបក្សសង្គមរាស្ត្រនិយម ទាំងប៉ុន្មាន យល់ថា ត្រូវតែនាំគ្នាចូលដើម្បីកុំឱ្យបែកបាក់សាមគ្គីគ្នា។

ចំណែក បក្សប្រជាធិបតេយ្យ យល់ថាបើមានតែគណបក្ស

សង្គមរាស្ត្រនិយមមួយប៉ុណ្ណោះ ការគ្រប់គ្រងរដ្ឋមិនអាចធ្វើទៅបានតាមលទ្ធិប្រជាធិបតេយ្យទេ គឺនៅតែជារបៀបឯកាធិបតេយ្យដដែលយ៉ាងនោះឯង ។ ការគ្រប់គ្រងរដ្ឋត្រូវមានគណបក្សច្រើន គឺមានឆ្វេង មានស្តាំ ។ អ្នកចាញ់សន្លឹកឆ្នោតគេត្រូវទុកឱ្យអ្នកឈ្នះឡើងកាន់អំណាច ។ ត្រូវយកមាគ៌ានយោបាយរបស់ខ្លួនមកថ្លែងជំរាបសភាថា ខ្លួនសន្យានឹងធ្វើអ្វីខ្លះក្នុងរយៈប៉ុន្មានខែ.ឆ្នាំ នឹងបានសម្រេច ។ល។

អ្នកដែលចាញ់ឆ្នោតត្រូវកត់សំគាល់ទុកនូវមាគ៌ានយោបាយរបស់អ្នកឈ្នះ ចាំប្រមើលមើលបើឃើញខុសពីមាគ៌ានយោបាយខ្លួនដែលបានថ្លែងជំរាបសភានោះ,សភាត្រូវកោះហៅរដ្ឋាភិបាលមកធ្វើសំនួរដេញដោលរកខុសត្រូវ នេះជារបៀបគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យ ។ល។

ពេលនោះ អង្គការក្រុមប្រឹក្សាជាតិ មិនទាន់អស់អាណត្តិនៅឡើយ នៅរង់ចាំដល់មានសមាជិកសភាថ្មីទើបផុតអាណត្តិក្រុមប្រឹក្សាជាតិ ។

ការបោះឆ្នោតលើកនេះ .មានតែគណបក្សពីរគឺ បក្សសង្គមរាស្ត្រនិយម និង បក្សប្រជាធិបតេយ្យ ហើយលោក ឯក-យីអ៊ុន បង្គាប់ឱ្យខ្ញុំឈរឈ្មោះខាង បក្សសង្គមរាស្ត្រនិយម តែខ្ញុំប្រកែកមិនទទួល ខ្ញុំជំរាបលោកថាខ្ញុំឈប់ធ្វើនយោបាយហើយ ។ លោក ហ៊ុយ-កន្ធុល ខាងបក្សប្រជាធិបតេយ្យឱ្យខ្ញុំឈរឈ្មោះនៅ ល្វាឯម ដដែល ខ្ញុំក៏ឆ្លើយបដិសេធដូចគ្នា ។

ការដែលខ្ញុំបដិសេធមិនព្រមធ្វើនយោបាយក្នុងគ្រានោះ ដោយហេតុឃើញស្តេចចូលធ្វើនយោបាយហើយចង់បង្កើតឱ្យ





មានគណបក្សតែមួយ ឃើញថាផ្ទុយនិងចិត្តគំនិតរបស់ខ្ញុំ ហើយម្យ៉ាងទៀតឮពាក្យចចាមអារាមថា បើបេក្ខជនបក្សសង្គមរាស្ត្រនិយមឈរឈ្មោះនៅមណ្ឌលណាហើយធ្លាក់ឆ្នោត,អភិបាលស្រុកនៅមណ្ឌលនោះត្រូវគេផ្លាស់ចេញក្នុង២៤ម៉ោងភ្លាម ។ល។

ឯការឃោសនាទៀត បក្សប្រជាធិតេយ្យ មិនអាចនិយាយឃោសនាពន្យល់រាស្ត្របានទេ ព្រោះនៅពេលឡើងនិយាយម្តងៗ គេតែងតែជួបប្រទះនិងអ្នកស្រែងស្រាស្រែកឡូឡាជាពាក្យជេរប្រមាថ មានគេវៃចោរពុងព្យាំង ធ្វើមិនឱ្យបក្សប្រជាធិបតេយ្យនិយាយឃោសនាបាន ។ល។

ចំណែកនៅមណ្ឌល *កាមខ្មែរកញ្ញាអ៊ុង*,ស្រុក ល្វាឯម,ខេត្តកណ្តាល ដែលខ្ញុំធ្លាប់ឈរឈ្មោះជាប់ឆ្នោតបីអាណត្តិរួចមកហើយ,ពេលនោះខ្ញុំមិនឈរឈ្មោះទេ,ព្រោះខ្ញុំឱ្យលោក *គាំ-វើក* ឈរជំនួសខ្ញុំវិញព្រមទាំងជួយប្រាក់ទៅគាត់ ១000 រៀលទៀតផង ។ លោក គាំ-វើក ឈរប៉ះនិងលោក *យ៉ែម-សំបូរ* បេក្ខជន គណបក្សសង្គមរាស្ត្រនិយម ។

ក្នុងពេលឃោសនាបោះឆ្នោត រវាងបេក្ខជន គាំវើក គណបក្សប្រជាធិបតេយ្យ និង បេក្ខជន យ៉ែមសំបូរ គណបក្សសង្គមរាស្ត្រនិយមនោះ ខ្ញុំសូមរំលឹករឿងមួយដូចតទៅ ៖

-លោក *ប៉ាល-ជួន* អភិបាល ខេត្តកណ្តាលបានកោះហៅខ្ញុំទៅការិយាល័យលោក ។ លុះខ្ញុំមកដល់,លោកប៉ាល-ជួនក៏ដកយកចុតហ្មាយមួយច្បាប់ពីវាំងមកអានឱ្យខ្ញុំស្តាប់មានសេចក្តីជាអាទិ៍ថា ៖

ខ្ញុំជាអ្នកជួយឃោសនាឱ្យលោក គាំ-វើក ប្រឆាំងនិង

គណបក្សសង្គមរាស្ត្រនិយមធ្វើឱ្យរាស្ត្រខូចសេចក្តីទុកចិត្តមកលើបក្សសង្គមរាស្ត្រនិយមអស់ ។ លោក យ៉ែម-សំបូរប្តឹងពីខ្ញុំទៅក្នុងវាំងថា រាស្ត្រមានជំនឿទៅលើលោក (បក្សសង្គមរាស្ត្រនិយម) ប្រមាណជា៩០ភាគរយទៅហើយ ។ លុះដល់លោក *ប៊ុន-ចាន់* ទៅឃោសនាជួយលោក គាំ-រេត ស្រាប់តែរាស្ត្រប្រែកចិត្ត បន្ថយជំនឿធ្លាក់ចុះពីលោក យ៉ាងច្រើន ។

លោក ចាល-ជូន ស្តីបន្ទោសខ្ញុំថា ៖

-លោកដឹងទេ គណបក្សសង្គមរាស្ត្រនិយមនេះ សម្តេចព្រះប្រមុខរដ្ឋលោកបង្កើត បើលោកប្រឆាំងនិងបក្សសង្គមរាស្ត្រនិយមគឺដូចជាលោកប្រឆាំងនិងសម្តេចព្រះប្រមុខរដ្ឋយ៉ាងនោះដែរ ។ល។

ខ្ញុំបដិសេធយ៉ាងដាច់ខាតមិនព្រមទទួលតាមពាក្យចោទមួលបង្កាច់នោះទេ ។ ខ្ញុំក៏សួរ ទៅលោក ចាល-ជូន វិញថា:

-តើឯកឧត្តមអាចបញ្ជាក់ទីកន្លែង-ថ្ងៃ-ខែ-និងពេលម៉ោងព្រមទាំងសាក្សីខ្លះផងបានឬទេ ? ព្រោះថាការឃោសនាត្រូវមានមនុស្សមកស្តាប់ច្រើនមិនលែង មានមនុស្សខ្លះស្គាល់មុខខ្ញុំផងជាមិនខាន ។ល។

លុះដល់ខ្ញុំទាររកភស្តុតាងក៏បាត់ ស្ងាត់ត្រឹមណោះទៅ។ល។ តាមដោយការយល់របស់ខ្ញុំ រឿងពាក្យចោទនេះជាពាក្យគំរាមកុំឱ្យខ្ញុំទៅជួយលោក គាំ-រ៉េត តែប៉ុណ្ណោះទេព្រោះគេដឹងថានៅក្នុងមណ្ឌលនេះមានគេ រាប់អានខ្ញុំច្រើនផងហើយខ្ញុំធ្លាប់ជាប់ឆ្នោតក្នុងមណ្ឌលនេះបីលើករួចមកហើយដែរ ។

តាមសេចក្តីខ្សឹបខ្សៀវរបស់លោក *នូ-ជិម* អភិបាលស្រុក





ល្វាឯម ដែលបានស្ទាបស្ទង់មើលមតិប្រជាជនទៅឃើញថាលោក យ៉ែម-សំបូរ មិនឈ្នះលោក គាំ-រ៉េត ទេ,ព្រោះមេសង្កាត់ដែលធ្លាប់ធ្វើការជូនលោកពីមុនមក ចូលជួយខាងលោក គាំ-រ៉េត ទាំងអស់ គេធ្វើតាមពាក្យផ្តាំផ្ញើរបស់លោកឱ្យជួយលោក គាំ-រ៉េត ទាំងអស់គ្នា ។ល។

មានពេលមួយលោក *នូ-ជិម* អភិបាលស្រុកល្វាឯមបានមកសូមជួបនិងខ្ញុំព្រោះលោក បានស្ទាបស្ទង់មើលមតិប្រជាជនទៅឃើញថាលោក គាំ-រ៉េត ត្រូវឈ្នះឆ្នោត ហេតុនេះលោក នូ-ជិម មកនិយាយសម្រុះសម្រួលគ្នារវាងលោក គាំ-រ៉េត និងលោក នូ-ជិម តាមរយៈខ្ញុំមុនដល់សន្ទឹកឆ្នោតចេញមកថា បើមានការប្រែប្រួលយ៉ាងណាកុំឱ្យអាក់អន់ចិត្តនិងគ្នាព្រោះមានគេបញ្ជាពីលើមកថាបើបេក្ខជនបក្សសង្គមរាស្ត្រនិយមនៅមណ្ឌលណាចាញ់ឆ្នោតពួកប្រជាធិបតេយ្យត្រូវអភិបាលស្រុកនោះទទួលខុសត្រូវ ។ អាស្រ័យហេតុនេះបើលោក គាំ-រ៉េត ឈ្នះ សូមលើកយកជ័យជំនះនេះដាក់ទៅលើលោក យ៉ែម-សំបូរ វិញដើម្បី តម្រូវចិត្តលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលបានបញ្ជាពីលើមក ។ល។

លុះបោះឆ្នោតហើយ ផលនៃការបោះឆ្នោតត្រូវបានទៅលោក គាំ-រ៉េត ។ លោក ចាល-ជូន ក៏ឈ្នះតែគេលើកទៅឱ្យលោក យ៉ែម-សំបូរ ឈ្នះទៅវិញ ព្រោះថាលោក គាំ-រ៉េត ឈ្នះតែម្នាក់ឯង មិនអាចធ្វើអ្វីកើតដែរ ។ល។

ក្នុងពេលនោះមានតែតំណាងរាស្ត្រគណបក្សសង្គមរាស្ត្រនិយម ទាំងអស់ចូលកាន់ រដ្ឋសភាជាតិ ។ ចំណែកក្រុមប្រឹក្សា-ជាតិ ត្រូវអស់អាណត្តិនៅថ្ងៃដែលតំណាងរាស្ត្រសង្គមរាស្ត្រនិយមចូលទទួលការ ។ល។

ក្នុងឆ្នាំដំបូងនៃសភានេះ,លោក*ទៅសែនកុសល* ហៅឈុំ

ធ្វើប្រធាន ។ លុះដល់ឆ្នាំទី២ ប្រធានសភាធ្លាក់ទៅលើលោក *ចេង-ហេង* វិញ ។ គណបក្សសង្គមរាស្ត្រនិយម គ្មានគូប្រឆាំងទេ ប្រៀបទៅនឹងគោអូសរទេះគ្មានអ្នកកាន់ជន្ទួញចាំញាក់ខ្សែតម្រូវផ្លូវ ។ល។

ក្នុងពេលនោះលោក *លន់-នល់* ធ្វើមេបញ្ជាការកងទ័ពជាតិ ។ ទ្រង់ *ស៊ីសុវត្ថិសិរិមតៈ* ធ្វើនាយករដ្ឋមន្ត្រីមិនបានយូរប៉ុន្មានត្រូវលោក លន់-នល់ ទម្លាក់ចេញ បានដាក់លោក ស៊ឹង-ង៉ុក-ថាន់ ឡើងធ្វើនាយករដ្ឋមន្ត្រី ។ លោក ស៊ឺង-ង៉ុក-ថាន់ធ្វើមិនបានយូរប៉ុន្មានស្រាប់តែមានភេរវជនម្នាក់មកបង្កប់គ្រាប់បែកចង់សម្លាប់លោកនៅក្បែរកំពែងខាងជើងរាជវាំងធ្វើឱ្យផ្ទុះស្លាក់រថយន្តលោកបណ្តាលឱ្យស្លាប់ទាហានម្នាក់និងរបួសពីរនាក់។ តាមអ្នកនិពន្ធសង្កេតហើយសន្និដ្ឋានមើលទៅហេតុការអុកឡុកទាំងប៉ុន្មានដែលកើតមានក្នុងពេលនោះ ហាក់បីដូចជាពុំមែនក្នុងរឿងជាតិវាជារឿងផលប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ ។ ក្នុងពេលនោះ មានលេចឮនូវពាក្យចចាមអារាម គេខ្សឹបខ្សៀវប្រាប់គ្នាតាមតៀមកាហ្វេថា :

-មានពេលមួយលោក *លន់-ណុន* ប្អូនលោក លន់-នល់ បានគិតគូក្នុងរឿងអ្វីមួយ ជាមួយលោក ស៊ឹង-ង៉ុក-ថាន់ ពុំបានសម្រេច ។ ប្រមាណមួយអាទិត្យក្រោយមកប៉ុណ្ណោះ ស្រាប់តែមានហេតុយ៉ាងនេះកើតឡើង ។ល។

& &
&





ថ្ងៃគេបើករដ្ឋសភា សម័យ បក្សសង្គមរាស្ត្រនិយម ថ្ងៃនោះគេឃើញសន្លឹកប័ណ្ណអនាមិកបិទតាមជញ្ជាំងរដ្ឋសភាប្រាំសន្លឹកដែលគេហៅត្រាក់ ។ ក្នុងត្រាក់នោះដាក់ថា ៖

-«សង្គមរាស្ត្រយំ» ។ សន្លឹកខ្លះដាក់ថា ៖

-«ប្រទេសក្រុងកម្ពុជា» ក្លាយទៅជាប្រទេស «រងកម្មពុំជា» វិញ។ ត្រាក់នេះគេបំបិទចោលពុំឱ្យផ្សាយ ។ល។

ក្នុងគ្រាឡើងកាន់អំណាចទទួលរៀបចំការរដ្ឋពុំមានឃើញផ្លូវស្រាលទេ ។ សហរដ្ឋអាមេរិកបានផ្តល់ជំនួយយ៉ាងម៉េចក៏ពុំបានរីកចំរើនឃើញចេះតែធ្លាក់ដុនដាបទៅរៀងរាល់ខែ-ឆ្នាំ។ ផលចំណេញច្រើនបានទៅលើឈ្មួញលក់ចេញទិញចូលនិងអ្នករដ្ឋការពុករលួយខ្លះតាំងពីលើដល់ក្រោម ។ ចំណែករាស្ត្របានទទួលផលពីរដ្ឋស្ទួចស្តើងពេកណាស់ ។ល។

ពេលនោះខ្ញុំឮថាអាមេរិកាំងប្រុងផ្ញើរគ្រឿងយុទ្ធសម្ភារៈពីស្រុកយួនមកតាំងទីបញ្ជាការនៅស្រុកខ្មែរវៃយួន ។ លុះចិនដឹងទាន់ក៏សូមយាង *សម្តេចសីហនុ* ទៅធ្វើទស្សនាការនៅប្រទេសចិន ។ ក្នុងពេលនោះចិនគេរៀបចំទទួលសម្តេចសីហនុយ៉ាងអធឹកអធម្ម.គ្រាន់តែមនុស្សតែងខ្លួនយ៉ាងស្អាតស្អំមកឈរចាំគ្រវីទង់ជាតិរួបប្រាសាទនិងទង់ជាតិចិនក្នុមួយនិស្ត មានចម្ងាយផ្លូវ៦គីឡូម៉ែត្រធ្វើឱ្យសម្តេច សីហនុ មានការរីករាយព្រះហឫទ័យជាយ៉ាងខ្លាំងក្នុងគ្រានោះ ។ ចិនសន្យាជួយកសាងរោងចក្រចំនួន៧ថ្វាយព្រះអង្គ ។ លុះព្រះអង្គយាងត្រឡប់មកពីប្រទេសចិនវិញទ្រង់បញ្ជាឱ្យកាត់ជំនួយអាមេរិកាំងចោលហើយថែមទាំងនាំគ្នាបះបោរធ្វើបាតុកម្មទៅវាយស្ថានទូតអាមេរិកកាំងបោចរោចខ្ទេចខ្ទីអស់ទៀតផងព្រោះអាងទៅលើរោងចក្រទាំង៧នោះ ហើយដឹកនាំអ្នករាជការទៅធ្វើការហត្ថកម្មផង ។ រោងចក្រជំនួយទាំង៧នោះគឺ ៖

១-រោងចក្រធ្វើស៊ីម៉ង់ត៍

២-រោងចក្រធ្វើអម្បោះ

៣-រោងចក្រតម្បាញក្រណាត់

៤-រោងចក្រធ្វើចានក្រឡៅ

៥-រោងចក្រធ្វើក្រដាស

៦-រោងចក្រធ្វើកែវ

៧-រោងចក្រធ្វើក្តារបន្ទះ

ឯរោងចក្រទាំង៧នេះតាមដែលខ្ញុំបានលេចឮពីលោកខ្លះគេបានធ្វើស្ថិតិគិតពីមុខចំណូលនិងចំណាយដែលបានពីរោងចក្រទាំងនេះសុទ្ធសឹងតែខាតទាំងអស់គ្មានចំណេញទេ ។

ចំណែករោងចក្រតម្បាញមួយ នៅកំពង់ចាម សម្តេចសីហនុ យកក្រណាត់ឈ្មោះថាក្រណាត់ «សង្គមរាស្ត្រនិយម» យកទៅបាចឱ្យរាស្ត្រអស់រាប់សិបលានទៅហើយ ។ រោងចក្រដទៃខ្លះទៀតលក់បានល្មមគ្រាន់តែឈ្នួលអ្នកធ្វើការប៉ុណ្ណោះ ។ រោងចក្រខ្លះ បានផលមក មិនបានទាំងគ្រប់គ្រាន់ សោហ៊ុយដែលចេញចំណាយទៅផង ។

កាលសម្តេចយាងទៅប្រទេសចិនកុម្មុយនិស្តនោះមិនមែនបានត្រឹមតែរោងចក្រប៉ុណ្ណោះទេថែមទាំងបានរបៀបធ្វើការហត្ថកម្មនោះមកទៀត ។ ព្រះអង្គទ្រង់ព្រះបញ្ជាទៅគ្រប់ក្រសួងឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់ទាំងអស់លះបង់ពេលវេលាទៅធ្វើការហត្ថកម្មកាប់គាស់ដីលើកទំនប់ឬជីកប្រឡាយជីកអណ្តូងផ្សេងៗ ម្នាក់ៗអស់៧ថ្ងៃផង ។ តាមអ្នកនិពន្ធគិតមើលកាលសម័យនោះ គ្មាននរណាហ៊ាននិយាយ ។ ខ្ញុំសូមបើករង្វង់ក្រចកគិតមើល ៖

-យកអ្នកមានប្រាក់បំណាច់មួយថ្ងៃ៥០០រៀល. គេយក ២១០រៀលជួលគូលីមួយថ្ងៃ៣០រៀលទៅធ្វើការកាប់ដីជំនួសរូបលោកធំនោះទាំង៧ថ្ងៃហើយលោកដើរលេងទាំង៧ថ្ងៃយ៉ាង





សប្បាយ ។ ចំណែកការប៉ុយរ៉ូគ្មានអ្នកណាហ៊ានសម្រេចត្រូវទុកចោលចាំលោកធំមកពីកាប់ដីវិញម្លោះហើយការងារទាំងឡាយត្រូវគាំងដំណើរអស់ពេល៧ថ្ងៃ ។ រដ្ឋត្រូវខាតនូវគំនិតបែបនេះយ៉ាងធំដោយមិនដឹងខ្លួន ។ បើគេយកត្រាក់ទ័រមួយឬពីរទៅប្រើជំនួសវិញអស់លោកទាំងអស់គ្នាដែលទៅកាប់គាស់ទាំង៧ថ្ងៃនេះមិនស្មើនិងត្រាក់ទ័រធ្វើមួយថ្ងៃហើយអាចបានផលច្រើនជាងទៀតផង ។ល។

នៅមានរឿងមួយទៀត អំពីការលក់ចេញទិញចូលនូវទំនិញនាំចេញចូលក្នុងរដ្ឋរាជការដកយកកិច្ចការទាំងនេះមកកាន់ផ្ទាល់ដៃដោយខ្លួនឯងវិញព្រោះយល់ឃើញថា ជំនួយបរទេសដែលគេជួយមកទាំងប៉ុន្មាន ពុំសូវបានផលទៅជាតិច្រើនបានតែទៅលើអ្នកជំនួញនិងចៅក្រសួងផ្សេងៗចែកចាយគ្នាស៊ីអស់ជាងពាក់កណ្តាលទៅហើយដូច្នេះរដ្ឋត្រូវផាត់ជំនួយពីបរទេសចេញក៏បង្កើតក្រុមអង្គការ សូណិចស៊ីម (Sonexim) និង សូណាព្រឹម (Sonaprim) នេះឡើង ដកយកការនាំចេញទិញចូលពីអ្នកជំនួញទាំងឡាយមកកាន់កាប់ដោយខ្លួនឯងវិញ ។

ត្រង់ណេះអ្នកនិពន្ធ ខ្ញុំនឹកអស់សំណើចព្រោះថា ៖ រដ្ឋពុំទាន់យល់កិច្ចការខាងជំនួញបានច្បាស់ផងទៅ យកការនេះមកកាន់ ហើយហៅអ្នកជំនួញមកធ្វើការឱ្យខ្លួនទាំងខាងនាំទំនិញចេញទាំងខាងនាំទំនិញចូលត្រូវនៅលើដៃថៅកែស្ទើរតែទាំងអស់ធ្វើឱ្យថៅកែសប្បាយចិត្តយ៉ាងខ្លាំង (ប្រៀបបានទៅនិងយកមាន់មកចិញ្ចឹមទុកក្នុងជង្រុកស្រូវយ៉ាងនោះឯង - មាន់ចឹកស្រូវលេបតាមចិត្ត ) មិនបាច់សូកបាន់អ្នកណាដូចមុនៗទៀតទេ។ល។

ចាប់តាំងពីបង្កើត *បក្សសង្គមរាស្ត្រនិយម* នេះឡើងរដ្ឋគ្មានការរីកចម្រើនទេ ។ រដ្ឋចេះតែផុនដាបទៅៗជាលំដាប់។ មានអ្នកខ្លះយកអំណាចរដ្ឋទៅប្រើយកប្រយោជន៍ផ្ទាល់ខ្លួន ដូច

ជានាំអង្ករទៅលក់ឱ្យពួកយៀកកុងយកប្រាក់ដុល្លាផ្ទាល់ខ្លួន ធ្វើឱ្យរដ្ឋខាតរូបិយប័ណ្ណជាតិអស់ជាច្រើន នាំឱ្យទាញតម្លៃប្រាក់រៀលធ្លាក់ចុះជាលំដាប់រៀងរាល់ឆ្នាំរហូតដល់ទៅនាយកធនាគារជាតិហាមឃាត់មិនស្តាប់ ក៏សូមលាលែងដកខ្លួនថយមិនហ៊ានទៅទទួលខុសត្រូវតទៅទៀត ។ មិនតែប៉ុណ្ណោះថែមទាំងលួចលាក់ដឹកនាំគ្រឿងយុទ្ធសម្ភារៈនិងសម្ភារៈពេទ្យព្រមទាំងឱសថទៅឱ្យយៀកកុងនោះថែមទៀត ធ្វើឱ្យ កករ ល្អក់ដល់លំនឹងអព្យាក្រឹតភាពរបស់ជាតិគួរឱ្យស្តាយ ។ល។

ខ្ញុំសូមងាកមកដំណាលអំពីរឿង *ខ្មែរឥស្សរៈ* ក្នុងគ្រានោះ ។ ការបង្កើត ខ្មែរឥស្សរៈ នេះដើម្បីឱ្យជាតិមានឯករាជ្យនិងអធិបតីជាតិ ពេញបរិបូរណ៍ ព្រោះថាឯករាជ្យក្នុងគ្រានោះវានៅក្នុងសហភាពបារាំងនៅឡើយ ។ បានជាជនជាតិយើងខ្លះគេមិនពេញចិត្តនិងឯករាជ្យបែបនេះគេក៏បង្កើតជាខ្មែរឥស្សរៈនេះឡើងមានឈ្មោះ ខ្លះៗ ដូចតទៅ ៖

លោក ស៊ីង-ង៉ុកថាន់,
លោក អៀ-ស៊ីចូវ,
លោក ដាបឈួនម្ជុលពេជ្រ,
លោក ប៊ុន-ចាន់ម៉ុល,
លោក អាចារ្យមុី-ប៊ុន,
លោក ហ៊ុលវង្សអនុភាព,
លោក អាចារ្យឃី,
ទ្រង់ ច័ន្ទរង្សី,
លោកសក្តិមួយធីង,
លោក ព្រាប-អ៊ិន,
លោក សៅ-អ៊ុយ ។ល។
មានឈ្មោះ ច្រើនទៀតខ្ញុំចាំមិនអស់ ។





ពួកនេះគេបានបែងចែកគ្នា ធ្វើការទៅតាមខេត្តខ្លះ ដូចជា ៖

នៅខេត្តបាត់ដំបង មានក្រុមមួយ

នៅខេត្តសៀមរាប មានក្រុមមួយ

នៅខេត្តតាកែវ,កំពង់ស្ពឺ,ស្វាយរៀង,ព្រៃវែង,កំពង់ចាម មានមេបញ្ជាការគេនៅលើភ្នំដងរែកគឺលោក ស៊ីង-ង៉ុក-ថាន់ ជាមេបញ្ជាការ ។

នៅពេលនោះពួកយួនក៏ស្រាប់តែបង្កើតពួក *យៀកមិញ* មកចូលលាយឡំជាមួយនិងខ្មែរឥស្សរៈនៅក្នុងខេត្ត ព្រៃវែងផងដែរ ។

កាលណោះពួកឥស្សរៈធ្វើការកៀបសង្កត់មកលើរាជរដ្ឋាភិបាលយ៉ាងខ្លាំង រហូតដល់ថ្នាក់បើកការចចារសម្រុះសម្រួលគ្នានៅ ក្រុងប៉ារីស ក៏បានស្ងប់មួយរយៈ ។ ចំណែកពួកយៀកកុងគេតវ៉ាសុំយកខេត្តខ្លះដែលជាប់និងប្រទេសយួនឱ្យពួកខ្មែរឥស្សរៈយៀកកុង ។ ខ្មែរមិនយល់ព្រម ពួកយៀកកុងក៏ដកថយទៅស្រុកយួនអស់ទៅ ។ លុះតមកខ្មែរឥស្សរៈភាគខ្លះមិនពេញចិត្តនិងរាជរដ្ឋាភិបាលគេនៅតែធ្វើសេចក្តីរំខាននិងរាជរដ្ឋាភិបាលពុំព្រមចុះចូល ។ លោក *អ៊ិន-តាំ* ចៅហ្វាយខេត្ត តាកែវបានចូលទៅនិយាយនិងខ្មែរឥស្សរៈនៅ ខេត្តតាកែវ ថា ៖



លោក *អ៊ិន-តាំ*

-សូមឱ្យចូលទៅជជែកចង្អុលហេតុផលប្រាប់គ្នាដើម្បីរកផ្លូវដោះស្រាយ ។ ពេលនោះលោក អ៊ិន-តាំ បានធានាលើជីវិតលោក *ព្រាប-អ៊ិន* ឱ្យមកនិយាយក្នុងសមាជវាលមេរុ ។

-នៅពេលដែលលោក ព្រាប-អ៊ិន កំពុងតែនិយាយនៅលើវេទិកាសមាជជាតិ,ស្រាប់តែមានអ្នកខ្លះចាប់អង្រួនកណ្ដឹង អ្នកខ្លះវាយចោតក្ដុងក្ដាំង,អ្នកខ្លះស្រែកឡូឡាមិនឱ្យលោកព្រាប-អ៊ិន និយាយកើត ។

លុះដល់ពេលយប់គេនាំយកលោក ព្រាប-អ៊ីន ទៅបាញ់សម្លាប់ចោលនៅព្រៃត្រពាំងក្រឡឹងក្នុងខេត្ត កំពង់ស្ពឺ ។ សម្ដេចសីហនុមានទាំងបញ្ជាឱ្យគេថតកុនហើយយកទៅបញ្ចាំងនៅក្នុងគ្រប់រោងកុន មុនពេលលេងរឿងនិមួយៗ ។

រាជរដ្ឋាភិបាលធ្វើយ៉ាងនេះខុសធ្ងន់ណាស់ ដោយមិនបានកាន់យកនូវពាក្យសច្ចៈ ហើយបែរជាទៅបោកប្រាសគេ យកមកសម្លាប់ដោយខ្វះការពិចារណា ។ ធ្វើយ៉ាងនេះមិនខុសអ្វីពីពួកប៉ុល-ពត ឡើយក្នុងគ្រានោះ ។



*ការប្រហារពួក « ខ្មែរសេរីក្បត់ជាតិ» ?*





អំពីរឿងលោក *ដាប-ឈួនម្ចាស់ពេជ្រ* នៅភូមិ *ពាដាក* ក្នុងខេត្ត សៀមរាប ។ ភូមិនេះនៅចម្ងាយពីក្រុងប្រមាណជា ១០គីឡូម៉ែត្រ ។ កាលណោះមានលោក *សាន-យុន* ធ្វើជាចៅហ្វាយខេត្តសៀមរាប ។ លោកបានចូលទៅនិយាយទាក់ទងបញ្ចុះបញ្ចូលយកលោក ដាប-ឈួន លុះត្រាតែបានសម្រេចនាំចូលមកសម្ដែងសេចក្ដីស្វាមីភក្ដិ៍ចំពោះព្រះភ័ក្ត្រព្រះករុណា ។ លោក ដាប-ឈួន មានកូនទាហានចំនួន៥០០នាក់ ។

រាជរដ្ឋាភិបាលបានបញ្ចូលរូបលោកទៅក្នុងគណរដ្ឋមន្ត្រី មានឋានៈជា រដ្ឋលេខាធិការការពារលើផ្ទៃប្រទេស មានទីស្នាក់ការ នៅខាងកើត *ស្ពានមុនីវង្ស* ហៅ *ជ្រោយចង្វារ* ។

លោកដាបឈួន មិនស្ទាវយល់របៀបគ្រប់គ្រង ខាងផ្លូវរដ្ឋបាល ក៏បាន អញ្ជើញ លោក *គង់-ហេង* ឱ្យធ្វើភូឈួយ ដើម្បីជួយចាត់ចែងការក្នុងរឿង សន្តិសុខលើផ្ទៃប្រទេស ។ល។

លោក ដាប-ឈួនចូលមករួមក្នុងសង្គមរាជរដ្ឋាភិបាលបានចំនួនតែពីរឆ្នាំប៉ុណ្ណោះ ក៏កើតមានការរកាំរកូសជាមួយនិងរាជរដ្ឋាភិបាលមិនដឹងពីរឿងអ្វីឬមួយដោយការណែនាំអំពីសំណាក់មហាអំណាចណាមួយផងក៏មិនដឹង ។ ស្រាប់តែមានថ្ងៃមួយលោកប្រមូលពួកកងទ័ពលោកទៅនៅព្រៃវិញមាននៅសល់ទាហានប្រមាណជា១០ភាគរយមិនព្រមទៅជាមួយលោកទេ ។ លុះដល់លោក លន់-នល់ យល់ឃើញនូវអកប្បកិរិយាលោក ដាប-ឈួន ធ្វើ យ៉ាងនេះក៏កើតមានការសង្ស័យក្រែងមានហេតុអ្វីមួយកើតឡើង ក៏ចាត់ការតាមទៅបង្ក្រាបដោយប្រើឧបាយកលមិនឱ្យលោក ដាប-ឈួន ដឹងខ្លួនមុន ។ លោក លន់-នល់ ប្រមូល

នាំយកទាហានលោក ដាប-ឈួន ដែលសល់ទាំងប៉ុន្មាន ចូលទៅវាយបង្ក្រាបបាញ់ សម្លាប់លោក ដាប-ឈួន ក្នុងព្រៃស្បែរ បន្ទាយភូមិបាដាកនោះស្លាប់ទៅ ហើយប្រមូលយកបានដុំមាសសុទ្ធចំនួន២០០ដុំ ដាក់ក្នុងហិបចំនួន២០ ។ ក្នុងមួយដុំមានទម្ងន់ ១គីឡូក្រាម ។ មាសទាំងនេះ,លោក *ជួង-សំអាន* ក្មួយលោក ស៊ីនសាន បានហៅខ្ញុំទៅពិនិត្យ ។ ដូច្នេះខ្ញុំបានឃើញនិងភ្នែកផ្ទាល់ ។ បើតាមការសន្និដ្ឋានចេញអំពីមជ្ឈដ្ឋានខ្លះគេយល់ថា មាសនេះប្រហែលជាមាសរបស់មហាអំណាចណាមួយគេឱ្យមកលោក ដាប-ឈួន ធ្វើសោហ៊ុយក្នុងការធ្វើរដ្ឋប្រហារនៃរបប សម្តេចសីហនុ នេះចេញព្រោះគេមិនពេញចិត្តនិងសម្តេច ដែលទៅបម្រើ យួន-ចិន នេះ ដែលជាគូប្រឆាំងនិងគេក្នុងគ្រានោះ ។ល។

លោក លន់-នល់ ក្រោយពីបានបង្ក្រាបលោក ដាប-ឈួន មានជោគជ័យមក អំណាចឥទ្ធិឫទ្ធិ៍របស់លោកក៏ឡើងមួយកំរិតទៀត ។ លោក លន់-នល់ ជាអតីតសមាជិក ក្នុងគណកម្មការនាយកនៃ *បក្សខេមរៈប៉ុណ្ណការ* ដែលមានរូបនាងកង្គីងជាសញ្ញាមាន *សម្តេចក្រុមព្រះមុនីរ៉េត* និង *ទ្រង់សិរិមតៈ* ជាអ្នកដឹកនាំ ។

នៅចុងក្រោយនេះសម្តេច សីហនុ ទ្រង់យល់ឃើញនូវស្ថានការណ៍ក្នុងប្រទេស កាន់តែដុនដាបទៅៗទាំងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានធ្វើដំណើរនយោបាយក្រៅប្រទេសចូលលាយឡំជាមួយនិងរបបកុម្មុយនិសនេះនៅតែដោះស្រាយខាងវិបត្តិន៍សេដ្ឋកិច្ចពុំរួច ព្រះអង្គប្រុងផ្លាស់ប្តូរនយោបាយថ្មី ទំនង





ប្រហែលបំរុងទៅទាក់ទងនិងមហាអំណាចខាងលិចវិញ ដោយការស្មានរបស់លោក *វៀម-សុផុន* អ្នកបំរើព្រះអង្គផ្ទាល់មកដំណាលប្រាប់អ្នកនិពន្ធខ្ញុំក្នុងពេលដែលលោកបញ្ជាទិញគ្រឿងរចនាខ្មែរអំពីខ្ញុំដែលធ្វើអំពីប្រាក់ និងលោហធាតុផ្សេងៗនេះចែកជាបួនប្រទេសចាត់ដាក់ជា៦ហិប ។ លោក *វៀម-សុផុន* បានឱ្យគូរអក្សរដាក់លើគ្របហិបទាំង៦នោះគឺទៅប្រទេសបារាំង ១ហិប,ទៅប្រទេសឆេកូស្លូវ៉ាគី១ហិប,ទៅប្រទេសរុស្សី២ហិប, ទៅចិនកុម្មុយនិស្ត២ហិប ។ល។

តាមដោយសេចក្តីសន្និដ្ឋានរបស់ខ្ញុំគឺថាព្រះអង្គមុននឹងដកខ្លួនចេញអំពីរបបកុម្មុយនិស្ត,ត្រូវព្រះអង្គយាងទៅពន្យល់អំពីផ្លូវនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃប្រទេសព្រះអង្គឱ្យគេបានយល់ជាមុនសិន ទើបសម្រេចធ្វើអ្វីជាខាងក្រោយមុននឹងចាប់ទាក់ទងជាមួយនិងលោកខាងលិច ឬ មហាអំណាចណាមួយនោះ ។ កាលព្រះអង្គបំរុងយាងទៅកាន់ប្រទេសទាំងបួននោះទ្រង់មានព្រះបន្ទូលថាព្រះអង្គទ្រង់យាងទៅព្យាបាលព្រះរោគធ្លាប់មានប្រចាំកាយព្រះអង្គដែលធ្លាប់យាងទៅព្យាបាលនៅប្រទេសបារាំងជារៀងរាល់ឆ្នាំ ។ល។

កាលព្រះអង្គ យាងទៅកាន់ប្រទេសបារាំង ក្នុងជំនាន់នោះមានយកមន្ត្រីចាស់ទុំជាច្រើនតាមហែព្រះអង្គទៅ,មានសម្តេច *ប៉ែន-នុត* ដែលជាទីប្រឹក្សាផ្ទាល់ព្រះអង្គ, លោក*ច័ន្ទ-ណាក*, លោក*ឡេង-ង៉ែត* ជាដើម ។ល។

កាលព្រះអង្គយាងទៅកាន់ស្រុកបារាំងក្នុងគ្រានោះជាផ្លូវបើកឱកាសឱ្យលោក *លន់-នល់* ត្រូវរ៉ូវជាមួយរដ្ឋសភាសង្គម-

រាស្ត្រនិយមដើម្បីដកព្រះអង្គឱ្យថយចេញ អំពីឆាកនយោបាយ ហើយថ្វាយព្រះអង្គឱ្យគង់នៅក្នុងរាជដំណែល ។ កាលណោះ គេចាត់ទ្រង់ *កន្តុល* និងលោក *ផែម-សំបូរ* ឱ្យទៅយាងព្រះអង្គត្រឡប់មកកាន់ប្រទេស ខ្មែរវិញ តែព្រះអង្គសំរេចព្រះទ័យដាច់ខាតមិនព្រមចូលមកកាន់ប្រទេសខ្មែរវិញឡើយ ហើយព្រះអង្គធ្វើដំណើរទៅកាន់ប្រទេសទាំងប៉ុន្មានដែលបានកំណត់ទុករួចហើយនោះទៅ ។ល។

ឯចំណែករដ្ឋសភានិងឧត្តមសេនីយ៍ លន់-នល់ ក៏បានសម្រេចចិត្តអនុម័តទម្លាក់សម្តេចចេញពីឆាកនយោបាយទៅ ។ ក្នុងគ្រានោះលោក *ចេង-ហេង* ធ្វើប្រធានរដ្ឋសភាក៏ត្រូវឡើងឋានៈជា *ប្រមុខរដ្ឋបណ្តោះអាសន្ន* រង់ចាំការបោះឆ្នោតជ្រើសតាំង *ប្រធានាធិបតី* ថ្មី ។ អស់រយៈពេលជាងមួយឆ្នាំ ទើប



លោក លន់នល់

មានការជ្រើសរើសប្រធានាធិបតីថ្មី ហើយលទ្ធផលនៃការបោះឆ្នោត ត្រូវបានទៅលោក លន់-នល់ ធ្វើជាប្រធានាធិបតីជា





ស្ថាពរ ។ ក្នុងពេលនោះលោកលន់-នល់ បានឡើងកាន់អំណាចជាប្រធានាធិបតីពេញច្បាប់ហើយមានឯកអគ្គរដ្ឋទូតចិនកុម្មុនិស្តប្រចាំក្រុងភ្នំពេញបានមកនិយាយនិងលោក លន់-នល់ សូមឱ្យទុកទីកន្លែងយួនដែលមកតាំងនៅក្នុងដីខ្មែរទាំងប៉ុន្មាន ដូចរោងពេទ្យនិងកន្លែងរោងជាងជួសជុលខាងទាហាន ទាំងអស់ សូមទុកនៅបណ្តោះអាសន្នសិន ។ ពេលនោះលោក លន់-នល់ មិនយល់ព្រម ចិនក៏បិទស្ថានទូតខ្លួនឈប់ទាក់ទងនិងខ្មែររហូតមក ។ល។



ទ្រង់ ស៊ីសុវត្ថិសិរីមតៈ

លោក លន់-នល់ ក៏ដាក់ទ្រង់ *ស៊ីសុវត្ថិសិរីមតៈ* ធ្វើជានាយករដ្ឋមន្ត្រី ។ ទ្រង់ សិរីមតៈ ធ្វើមិនបានយូរប៉ុន្មានក៏ត្រូវលោក លន់-នល់ បញ្ឈប់ចេញដំណែងគ្មានឱ្យធ្វើអ្វីទាំងអស់។

តមក គេតាំងលោក *សឺង-ង៉ុកថាន់* ឱ្យធ្វើនាយករដ្ឋមន្ត្រីតទៅទៀត ។ លោក សឺង-ង៉ុកថាន់ ធ្វើ ការមិនបានយូរប៉ុន្មានស្រាប់តែមានគេលួចធ្វើវិទ្ធង្សនាដាក់គ្រាប់បែកមីន.ធ្វើឱ្យផ្ទុះស្លាប់ក្បួនរថយន្តលោកធ្វើដំណើរទៅធ្វើការត្រង់វាលមេរុំ

ក្បែរកំផែងវាំងធ្វើឱ្យស្លាប់ទាហានម្នាក់និងរបួសខ្លះ ។

លោក ស៊ឹង-ង៉ុកថាន់ ត្រូវផ្លាស់ចេញពីមុខដំណែង ត ទៅទៀត ។ល។

កិច្ចការលោក លន់-នល់ ទាំងអស់ តាមការឱ្យបខៀវ ចេញអំពីមជ្ឈដ្ឋានខ្លះ ហាក់បីដូចជានៅក្រោមការចាត់ចែង របស់លោក *លន់-ណុន* ជាប្អូនទៅវិញ ។ គេពុំឃើញមាន ការរីកចំរើនអ្វីឡើយ។ ល។

អំពីសម្តេច សីហនុ ក្រោយដែលលោក លន់-នល់ បាន ទំលាក់ចេញពីប្រមុខរដ្ឋ. ព្រះអង្គគង់ពុំសុខក៏ចូលធ្វើរណសិរ្ស រួបរួមជាតិឥណ្ឌូចិនជាមួយពួកយួនហាណូយ ។ ពេលនោះកើត មានខ្មែរក្រហមនិងពួកវៀតមិញរុកគួនពាសពេញ ។ ប្រទេស ខ្មែរលែងទៅជា «កោះសន្តិភាព » ហើយ តែក្លាយទៅជាកោះ «អសន្តិភាព » ទៅវិញ ។

ពួកហាណូយបាន «សម្តេចឪ»ស្នីគ្រចូលក្នុងក្រុមខ្លួនហើយ គេយល់បានថា ព្រះអង្គនៅមានប្រជាប្រិយ៍ពីសំណាក់អ្នកស្រែ ចំការនៅឡើយ ព្រោះព្រះអង្គធ្លាប់បោះបាចក្រណាត់សំពត់ «សង្គមរាស្ត្រនិយម» ឱ្យគេ,និងយកកុនដើរក្លដោយព្រះអង្គផ្ទាល់ និងអ្នកកំប្លែងផ្សេងៗទៅប្រទានឱ្យរាស្ត្រសប្បាយម្តងៗ ។ល។

យួនយល់នូវចំណុចខ្សោយរបស់ខ្មែរបែបនេះ គេក៏យក ព្រះនាមព្រះអង្គមកធ្វើនុយបិទផ្លែសន្ទូចរួចគេស្ទូចយកជ័យជំនះ លើ កងទ័ព លន់-នល់ យ៉ាងស្រួល ។

គេប្រើពាក្យឃោសនាថា ៖ «ពួកយើងវៃដេញកំចាត់ពួក អា លន់-នល់ ចេញ,យកស្រុកថ្វាយសម្តេចឪវិញដែលស្រប





និងអំពើឃោរឃៅរបស់កងទាហាន លន់-នល់ ចូលទៅក្នុង ភូមិមួយៗ មិនបានធ្វើឱ្យអ្នកស្រុកត្រេកអររីករាយ ត្រឡប់ទៅ ជាភ័យខ្លាចចូលទៅ រករាន ចោទប្រកាន់ គ្នាថា ជា «បក្សពួក ខ្មែរក្រហម » មានកន្លែងខ្លះម្ចាស់ផ្ទះមិននៅ គេចូលទៅរុះរើយក ទីលំនៅគ្នា ដាក់ឡានយកមកលក់ឬសង់យកជាប្រយោជន៍ ផ្ទាល់ខ្លួនក៏មាន ។ ខ្លះក៏ទៅកាប់យកដើមឫស្សីឈើព្រៃ នៅ ក្នុងភូមិគ្នាមានស្វាយក្រូចខ្នុរជាដើមដាក់ឡានទាហានដឹកយក មកលក់នៅភ្នំពេញក៏មាន ធ្វើឱ្យអ្នកស្រុកសម្តែងការឈឺចាប់ ហួសប្រមាណ ។ល។

ផ្ទុយគ្នានិងពួក *ទាហានខ្មែរក្រហម* និង ពួក *វៀតកុង* គេឃាត្រាទ័ព «លប់ដានស្នាមជើង »កងទាហាន លន់-នល់បាន យ៉ាងប្រសើរបំផុត ។

មុននឹងគេចូលទៅ គេសំពះសួរម្ចាស់ផ្ទះមានលោកយាយ លោកតា.មីង.ពូ ជាដើម ។ល។ សូមឱ្យគ្នាដាំបាយចំអិនម្ហូប អាហារហើយវែកទឹកដាក់ពាង ។ លុះដល់ចេញដំណើរតទៅ មុខទៀត គេលុតជង្គង់ សំពះលាថែមទាំងបោសសំអាតទីកន្លែង រួចហើយទើបសំពះលាចេញទៅ ។

ឯល្បិច « *ខ្មែរក្រហមពួកវៀតកុង* » នៅភូមិជួរខាងកើត ទន្លេមេគង្គ មានភូមិ,សង្កាត់ ខ្លះ ដូចជាភូមិ អន្លង់ទ្រា,ពាមស្តី, ព្រែកជ្រៃ ជាដើម ភូមិទាំងនេះមានពួកវៀតកុងនិងខ្មែរក្រហម គេដកដាលផ្លាស់ផ្លូវ មេភូមិបានតាមចិត្ត ។

ល្បិចគេសម្រាប់ខ្មែរគឺថា ៖

បើគេចូលទៅយកភូមិស្រុកណាបានហើយគេសួរអ្នក

ស្រុកនៅភូមិនោះ គេរកមុខអ្នកណាដែលចេះពូកែនិយាយធ្វើឱ្យអ្នកស្រុកជឿស្តាប់ ។ អ្នកស្រុកខ្មែរជាមនុស្សស្លូតត្រង់ ក៏ឆ្លើយប្រាប់គេទៅតាមចំណាំខ្លួនដែលធ្លាប់ដឹងធ្លាប់ស្តាប់ថា មានអ្នកនេះឬអ្នកនោះ ។ គេក៏ចូលទៅសរសើរបញ្ជោរអ្នកនោះលើកទឹកចិត្ត ហើយសូមអញ្ជើញឱ្យទៅជួយពន្យល់អ្នកភូមិផង ព្រោះអ្នកខាងណោះពុំសូវចេះនិយាយឱ្យរាស្ត្រស្តាប់យល់ទេ ។ អ្នកនោះឯងក៏អញ្ជើញទៅតាមពាក្យគេបញ្ចើចបញ្ចើ ។

សត្រូវយកមនុស្សណាដែលកាចសាហាវ.ជាអ្នកលេងដៃឆើត ធ្វើឱ្យអ្នកស្រុកខ្លាចរអាគ្រប់ៗគ្នា មកត្រួតត្រា ប្រព្រឹត្តអំពើព្រៃផ្សៃមកលើស្ត្រី.ក្មេងជំទង់ ។ គេញុះញង់មេដឹកនាំចាស់ឱ្យប្រុងប្រយ័ត្នមេថ្មី. ខ្លាចអ្នកនោះដណ្តើមកន្លែង ។ ម្ល៉ោះហើយមេចាស់និងមេថ្មីក៏គិតតែពីកាប់សម្លាប់គ្នាទៅតាមរបៀប «សត្រូវគិចសង្គ្រាប្រជល់គ្នា» ដោយមិនដឹងខ្លួនទៅ ។

អ្នកមិនបានគិតឱ្យជិតដល់ ទាំងខ្មែរ.ទាំងបរទេសជិតឆ្ងាយក៏មើលទៅឃើញតែ ខ្មែរ ឈ្លោះកាប់សម្លាប់ ខ្មែរគ្នាឯង ។

តាមការកត់សំគាល់របស់អ្នកស្រុកជាហូរហែមក. ខ្មែរក្រហមដែលនៅក្រោមបញ្ជាពួកយៀកកុង គ្មានគំនិតគិតគូឬធ្វើអ្វីបានតាមចិត្តទេ ។ គំនិតទាំងអស់ចេញពីយៀកកុង រីឯពួកខ្មែរក្រហមទាំងនោះ ធ្វើបានតែចាំសម្លុតរៃអង្គាសលុយ.អង្ករ ពីអ្នកស្រុករបស់ខ្លួនតែប៉ុណ្ណោះ ។

ពួកខ្មែរក្រហមនិងពួកយៀកកុង. វាច្បាំងនិងទាហានលន់នល់ នៅពេលនោះមិនសូវពិបាកប៉ុន្មានទេ ។ ព្រោះពួកវាមានការគាំទ្រពីអ្នកស្រុកដែលជាលទ្ធផលនៃសង្គ្រាម





ចិត្តសាស្ត្ររបស់ពួកយៀកកុង ។

ការដែលទាហាន លន់នល់ ចាញ់ដៃនៅពេលនោះ មានហេតុបួនយ៉ាង ៖

១- យៀងកុង យកព្រះនាមសម្តេចសីហនុ មកធ្វើជានុយ ស្ទូចយកទាហាន លន់នល់ ។ គេប្រកាសថា គេមកជួយរំដោះ យកស្រុកថ្វាយសម្តេចឪ វិញ ។ នៅពេលនោះមានទាហានខ្លះយកអាវុធរត់ទៅចុះចូលខាងគេអស់ជាច្រើនដែរ ។

២-មកពីកងទាហាន លន់នល់ ខ្វះវិន័យ ។ ពេលចូលទៅក្នុងភូមិនិមួយៗ មានទាហានខ្លះគិតតែពីធ្វើបាប រាស្ត្ររបស់សាសន៍ឯង ធ្វើឱ្យអ្នកស្រុកខូចទឹកចិត្តដោយសារអំពើមិនគប្បីនេះ ។

៣-មកពីនាយទោហ៊ានមិនបាននៅជាមួយនិងកូនទាហាន បណ្តោយឱ្យទ័ពភ័យច្រូលច្របល់ គិតតែពីដកថយនៅពេលណាដែលឮថាមានខ្មាំងនៅខាងណេះឬខាងណោះ ។

៤-ឮថាគ្មានបើកប្រាក់ខែឱ្យកូនទាហានថែមទៀតផង ។ ដូច្នេះតើមានទឹកចិត្តឯណានិងច្បាំង ហើយតើគេច្បាំងដើម្បីធ្វើអី ?

គឺមកពីហេតុទាំងបួននេះហើយ ដែលបានបើកផ្លូវឱ្យយួនយៀកកុងដើរចូលមកដល់ឃុំអារីយ៍ក្សត្រខាងកើតទន្លេចតុមុខទល់មុខក្រុងភ្នំពេញ ហើយឆ្លងទន្លេ មកដាក់មីនបំបាក់ស្ពាន «*ជ្រោយចង្វារ*» ទាំងកណ្តាលថ្ងៃត្រង់ បានយ៉ាងស្រួល ។

វាដាក់មីនបំបាក់ ស្ពានជ្រោយចង្វារ នេះចំនួនពីរលើក:

-លើកទីមួយ. នៅពេលម៉ោង១ថ្ងៃរសៀល.វាយករថយន្ត

កាម៉្យោណែត (camionnette) បង្កប់គ្រាប់បែកនៅក្នុងធុងកោងកាង ។ រថយន្តនោះបើកឡើងហើយទៅឈប់នៅចំពាក់កណ្តាលស្ពាន ។ ពីរបីនាទីក្រោយមក, គ្រាប់បែកក៏ផ្ទុះឡើងធ្វើឱ្យស្ពានរបេះមួយចំហៀង ធ្វើឱ្យឡានបើកបរលែងកើត តែមនុស្សម្នាអាចដើរចុះឡើងបាន ។

លើកទី២, វាដាក់នៅចំពេលយប់ភ្ជុំបិណ្ឌ ដោយយកគ្រាប់បែកទៅចងក្រោមស្ពាន ។ ស្ពានក៏ដាច់ជាពីរកំណាត់នៅពេលនោះទៅ ។ មុនវាបំបាក់ស្ពាន, ពួកយៀកកុង បានចូលទៅយករទេះគង់ក្នុងបន្ទាយ *ភូមិឫស្សីកែវ* ត្រង់គល់ស្ពាននោះ។ វាលួចបានរទេះគង់ពីរ ហើយវាបញ្ជេះបើកបរទៅទិសខាងជើង ។ កងទាហាន លន់នល់ ដេញតាម តែយកមកវិញមិនបាន តែបានធ្វើឱ្យគ្នាវាស្លាប់នៅលើរទេះគង់ចំនួនបីនាក់។

ឯចំណែកខាងស្ពានដែលបាក់នោះ, គេបាញ់ស្លាប់៨នាក់។ ឬករួមក្នុងយប់នោះ, ទាហាន លន់នល់ បានបាញ់ពួកយៀកកុងនិងខ្មែរក្រហមស្លាប់អស់ចំនួន ១១នាក់ គឺ ខ្មែរក្រហម ៤នាក់,និងយៀកកុង ៧នាក់ ។ គេបានយកខ្មោចទាំងនោះមកដាក់តម្រៀបត្រង់គល់ស្ពានខាងកើត ឱ្យអ្នកស្រុកមើល ។

ចាប់តាំងពីថ្ងៃនោះមក, អ្នកនិពន្ធខ្ញុំពុំបាននៅស្រុកខ្មែរទៀតទេ ដោយជាប់បំពេញបេសកកម្មសំរាប់ក្រុមហ៊ុនសុខានៅប្រទេសថៃ ហើយក៏ធ្វើដំណើរមកកាន់ប្រទេសបារាំងជាបន្តមករហូតដល់សព្វថ្ងៃនេះ (ឆ្នាំ១៩៩៥)។ តាំងពីពេលនោះមក, ខ្ញុំលែងបានឃើញអ្វីទៀតហើយ ។

លុះពេលខ្ញុំនៅ ប្រទេសថៃ បានរយៈពេលប្រហែលមួយ





ខែ, ខ្ញុំស្រាប់តែបានទទួលដំណឹងថា ស្រុកខ្មែរធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មាំងទៅហើយ ។ កន្លះខែក្រោយពីខ្មាំងដណ្តើមស្រុកខ្មែរបានមក,ខ្ញុំបានចេញពីទីក្រុងបាងកកទៅជួបខ្មែរភៀសខ្លួននៅតាមជំរុំស្រុកអារញ្ញជាយដែនខ្មែរ-ថៃ ។ អ្នកភៀសខ្លួនទាំងនោះបានប្រាប់ខ្ញុំថា : ពួកខ្មែរក្រហមខ្មែរ និងខ្មែរក្រហមយៀកកុងកំពុងតែឈ្លោះគ្នាពីរឿងដេញប្រជាជនចេញពីទីក្រុងភ្នំពេញ។

ខ្មែរក្រហមពួក ហ៊ូយន់, ហ៊ូនីម, ទ្រង់ភូរិស្សរា, ជ័យជុំ, អេងសុទ្ធ, ជីគឹមអាន, សៀងបៅសែ, អ៊ុនអ៊ិម ពួកទាំងនេះសុទ្ធសឹងតែមានវិជ្ជាថ្នាក់ខ្ពស់ៗទាំងអស់ ។ គេប្រឆាំងនិងខ្មែរយៀកកុងមិនព្រមឱ្យរាស្ត្រថយចេញពីក្រុងឬទីប្រជុំជនយ៉ាងដាច់ខាត ។ ពួកខ្មែរក្រហម-យៀកកុង ខឹងនិងអ្នកចេះដឹងប្រឆាំងវា, វាដេញតាមបាញ់សម្លាប់ចោលទាំងអស់, ទាំងប្រពន្ធទាំងកូនគ្មានសល់មួយទេ ។

ឯពួកប៉ុលពត, អៀងសារី ពួកនេះពីដើមវាជាពួកយៀកកុងជាមួយគ្នា ។ លុះយកភ្នំពេញបានស៊ប់ហើយ, គេប្រើឧបាយកលយួនធ្វើជាសូមលាទៅស្រុកវិញ ។ វាប្រមូលយកគ្រឿងអាវុធ យុទ្ធោបករណ៍ធ្ងន់ស្រាលទាំងប៉ុន្មាន ហើយប្រារព្ធធ្វើពិធីសូមលា ពួកប៉ុលពត ហើយវានាំពួកកងទាហានវាវិលត្រឡប់ទៅស្រុកវិញ ។ លុះបានចូលស្រុកវារួចហើយ,វាធ្វើកលយកលេសឱ្យពួកយួនគ្នាវាចូលមកសង់ផ្ទះលើទឹកដីខ្មែរ ។ លុះដល់ពួក ប៉ុលពត ឃើញមានស្ថានការណ៍បែបនេះ ក៏ចាត់ទាហានទៅប្រាប់ឱ្យថយចេញ ។ ពួកយួនមិនព្រមចេញក៏ទៅ

ដេញបង្ក្រាបដោយអាវុធ ។ ពួកយួនយៀកកុងយកលេសរឿងនេះ ក៏នាំទាហានចូលមកឈ្លានពានវាយយកក្រុងភ្នំពេញបានពីដៃ ប៉ុលពត ទៅវិញ ។ ពេលនោះហើយ ពួកយៀកកុងជិះសេះលែងដៃ ដឹកជញ្ជូនយករបស់ទ្រព្យរដ្ឋនិងសម្បត្តិឯកជនខ្មែរ ដាក់ទូកកប៉ាល់ និង ដឹកតាមរថយន្តពេញៗនាំយកទៅព្រៃនគរ ។ រួចមកវារៀបចំចាត់តាំងជនជាតិយើងខ្លះឱ្យចាំទទួលខុសត្រូវជួសគេ ធ្វើជាដៃជើងបំរើការរបស់គេដើម្បីធ្វើជាឡប់ខ្សែងាយក្នុងល្បិចកលឈ្លានពានលេបប្រទេសជាតិថែមទាំងគួបង់កាត់យកផ្ទៃដីនិងដែនទឹកសមុទ្រខ្មែរខ្លះអស់ជាច្រើនគីឡូម៉ែត្រ នោះទៀតផង ។ រួចហើយធ្វើឫកជាដកកងទ័ពថយ ហើយមានធ្វើពិធីផ្សេងៗ លាថយចេញពីទឹកដីខ្មែរដើម្បីបង្ហាញឱ្យខ្មែរនិងបរទេសជិតឆ្ងាយជឿ បញ្ជាក់ថាគេមិនមែនមកឈ្លានពានយកទឹកដីខ្មែរទេ ។ តែគេជ្រៀតចូលមកតាមទ្វារក្រោយ នៅស្ទើរតែពាសពេញប្រទេសខ្មែររួចទៅហើយ ដូចអស់លោកនាងអ្នកបានជ្រាបមកស្រាប់ហើយ ។





## អវសានកថា

អ្នកនិពន្ធខ្ញុំបានដំណាលជំរាបមកទាំងប៉ុន្មានក្នុងអត្ថបទនេះ ពុំបានហូរហែសព្វគ្រប់ ព្រមទាំងបញ្ជាក់អំពីឆ្នាំខែថ្ងៃពេលវេលានូវហេតុការដែលកើតមានមកទាំងប៉ុន្មានឱ្យបានច្បាស់លាស់នោះផងទេ ។ ព្រោះមានការភ្លេចភ្លាំងខ្លះពុំបានចាំសព្វគ្រប់ ដោយហេតុរឿងរ៉ាវនេះបានកន្លងផុតមកអស់រយៈវេលា ៤៥ឆ្នាំកន្លងមកហើយ ។ ដូច្នេះខ្ញុំសូមអភ័យទោសអំពីសំណាក់លោកអ្នកអានដោយសេចក្ដីករុណា ។

ខ្ញុំខំរកនឹកដកស្រង់ចេញមកអំពីការចងចាំខ្លះ យកមកបកស្រាយជូនអស់លោកអ្នកនាង ដែលពុំទាន់បានជ្រាបនោះឱ្យបានជ្រាបខ្លះ គ្រាន់ជាផ្លូវគំនិតដល់កូនចៅខ្មែរទៅអនាគតកុំឱ្យកប់បាត់ចោលជាអាសារបង់តែប៉ុណ្ណោះ ។

(ចប់)